រ.គោចន

# តែងសេចក្ដីខ្មែរ

* មធ្យមដ្ឋាន នឹង ឧត្ដមដ្ឋាន *

* វិញ្ញាបនប័ត្របឋមសិក្សាបំពេញវិជ្ជា *



# RÉDACTION KHMÈRE

COURS MOYEN & SUPERIEUR

CERTIFICAT D'ÉTUDES PRIMAIRES COMPLÉMENTAIRES

បណ្ណាគារ សេរីរដ្ឋ ភ្នំពេញ

CA10

# តែងសេចក្ដីខ្មែរ

សម្រាប់

* មធ្យមដ្ឋាន និង ឧត្ដមដ្ឋាន *

* វិញ្ញាបនប័ត្របឋមសិក្សាបំពេញវិជ្ជា *


រៀបរៀងដោយ

រ. គោវិទ



ការផ្សាយរបស់

បណ្ណាគារ សេរីរដ្ឋ

លេខ ៥, វិថីតេជោដំឌិន

ភ្នំពេញ

ព.ស. ២៥០១ - គ.ស. ១៩៥៨



រក្សាសិទ្ធិ

# អារម្ភកថា

មុននឹងសៀវភៅនេះកើតឡើង, ខ្ញុំបានស្រាវជ្រាវក្បួនខ្នាតខាងការតែងសេចក្តីទាំងភាសាខ្មែរនិងបរទេសជាច្រើន អស់ពេលវេលាជាច្រើនឆ្នាំ ដើម្បីយកមកចងក្រងឲ្យទៅជារបៀបមួយប្រកបដោយកម្មវិធីនិងសកម្មភាព ស្រណុករៀន ស្រណុកចាំ ព្រមទាំងស្រណុកសង្កេត ។ បាទ! ពិតណាស់ហើយ ការខ្វះខាតខាងក្បួនខ្នាតសិក្សា ចេះតែមានជាដរាប ។ ប៉ុន្តែ ក្បួនខ្នាតមិនសូវល្អ យើងមិនពេញចិត្តដែរ ក្បួនខ្នាតល្អ ត្រឹមត្រូវ ជាឫសគល់នៃអក្សរសាស្ត្រជាតិពិត ៗ ទើបយើងពេញចិត្ត ចង់បានចង់ក្រេបជញ្ជក់យករសជាតិ ឬខ្លឹមសារ នៃក្បួនខ្នាតនោះ ។

រីសៀវភៅ «តែងសេចក្តីខ្មែរ» នេះ គឺជាកល្យាណមិត្តមួយដ៏ប្រសើរ សម្រាប់ជួយបំភ្លឺយោបល់សិស្សថ្នាក់មធ្យមដ្ឋានទី ១ - ទី ២ - ឧត្តមដ្ឋាន ព្រមទាំងបេក្ខជនប្រុស - ស្រី ក្នុងការតែងសេចក្តីប្រឡងយកវិញ្ញាបនប័ត្របឋមសិក្សាបំពេញវិជ្ជា ។

ជាអវសាន, អ្នកនិពន្ធ សូមជំរាបមិត្តថា: លោកគ្រូមានការពិសោធន៍ច្រើន អាចបង្រៀនសិស្សឲ្យឆាប់ចេះ ឆាប់យល់បាន ៗ ប៉ុន្តែ បើសិស្សខ្ជិល ក៏គ្រូមិនអាចនឹងធ្វើវិជ្ជាបញ្ចូលទៅក្នុងខួរក្បាលសិស្សបានឡើយ ។

ដូច្នេះ អ្នកសិក្សា គប្បីពិនិត្យនឹងត្រិះរិះ របៀបស្រណុកចាំ ស្រណុកចេះ នឹងរបៀបល្អ ប្រសើរក្នុងការតែង ដែលជាបាតុកម្មនៃគំនិត សតិ, បញ្ញា, ស្មារតី របស់យើងដោយខ្លួនឯងទៀតផង ។

សូមឲ្យវឌ្ឍនភាពខាងអក្សរសាស្ត្រចំរើនជឿនលឿនទៅមុខជាដរាប ។

ភ្នំពេញ, ទី ២៥ មីនា ១៩៥៨

រ.គោវិទ

# អក្សរសង្ខេបៗ៖

## ដែលប្រើក្នុងសៀវភៅនេះ

| ពាក្យបំព្រួញ | ត្រូវអានថា | បារាំងថា |
|---|---|---|
| កិ. | កិរិយាសព្ទ | verbe |
| កិ.វិ. | កិរិយាវិសេសន៍ | adverbe |
| គុ. | គុណសព្ទ | adjectif |
| ន. | នាមសព្ទ | nom |
| នបុំ. | នបុំសកលិង្គ | genre neutre |
| ន.ប្រ. | ន័យប្រៀប | sens figuré |
| បុំ. | បុំលិង្គ | masculin |
| ពហុ. | ពហុវចនៈ | pluriel |
| ឥ. | ឥត្ថីលិង្គ | féminin |
| ឧ. | ឧទានសព្ទ | interjection |
| ឧទា. | ឧទាហរណ៍ | exemple |
| ឯក. | ឯកវចនៈ | singulier |

# ការតែងសេចក្ដី

ការតែងសេចក្ដី គឺជាកិច្ចមួយ ដែលយើងត្រូវសរសេ បញ្ជាក់អំពីការត្រិះរិះ, ការពិនិត្យនឹងការយល់ឃើញរបស់យើ ឲ្យត្រូវទៅតាមប្រធានដែលគេចោទសួរ ។

ពិសេសទៅទៀត, បើយើងចង់ឲ្យបានសេចក្ដីត្រឹមត្រូវ នោះត្រូវយើងចេះប្រើពាក្យពេចន៍ ឃ្លាល្បះ សំរិតសំរាំង សមរម្យតាមលំនាំដូចតទៅ ៖

## ១. ការរៀបចំ :

ក) ត្រូវរៀបសេចក្ដីឲ្យទាក់ទងគ្នា ពីដើមរហូតដល់ចប់

ខ) តែងកុំឲ្យច្របូកច្របល់គ្នា រៀបជាលំដាប់តាមរបៀ ហូរហែ ។

គ) បញ្ចប់សេចក្ដី ឲ្យពីរោះ ហើយឲ្យទាក់អារម្មណ៍អ្ន អាន ។

## ២. គោលនៃការតែងសេចក្ដី :

ក) ត្រូវចេះពិនិត្យសកម្មភាពនានា ហើយរៀបសេចក្ដីឲ្យសមហេតុសមផល ។

ខ) ត្រូវរើសរកពាក្យមកអធិប្បាយ ឲ្យបានច្បាស់លាស់ គឺចេះរៀបពាក្យឲ្យគេងាយយល់ងាយស្ដាប់ ហើយល្អត្រឹមត្រូវ។

គ )-ត្រូវសរសេរដោយចេះកែសម្រួលខ្លួនឯង គឺត្រូវចេះជ្រើសរើសរកពាក្យណាគួរប្រើ និងមិនគួរប្រើ ។

ឃ ) ត្រូវសរសេរអក្សរផ្ចិតផ្ចង់ ស្អាតជារបៀប ស្រណុកដល់អ្នកមើល ។

## ៣. កិច្ចត្រូវដឹង :

ក ) យើងត្រូវអានសៀវភៅរបស់អ្នកនិពន្ធណា ដែលសរសេរល្អត្រឹមត្រូវ ពិនិត្យសង្កេតនូវសេចក្ដីក្នុងនោះឲ្យយល់ច្បាស់ រួចយើងជ្រើសរើសចងក្រងយកពាក្យល្អៗ របស់គេ មកទុកសម្រាប់ប្រើប្រាស់ក្នុងការតែងសេចក្ដីរបស់យើង តែមិនត្រូវចម្លង

ពាក្យឲ្យជួបគេស្មោះទាំងអស់នោះទេ ។

១) ត្រូវចេះពិនិត្យនូវរបៀបតែង, អក្ខរាវិរុទ្ធ និង វេយ្យាករណ៍ ដើម្បីជៀសវាងពីការខុសគ្គងផ្សេង ៗ ។

គ) កាលបើគេដាក់ប្រធានឲ្យ យើងមិនត្រូវចាប់សរសេរ ឲ្យចប់មួយរំពេចនោះទេ ត្រូវយើងសង្កេតឲ្យហ្មត់ចត់សិន ។ ត្រូវ អានជាច្រើនដង ហើយគូសបំណាំពីក្រោមពាក្យណា ដែល សំខាន់ៗ ដើម្បីយកពាក្យនោះមកវាយបំបែកសេចក្ដី ហោទសួរខ្លួន ឯង ឲ្យអស់ចុះអស់គល់ដរាបដល់យល់ថា តើគេចង់និយាយពី អ្វី ? រួចកត់កង់សំណៅ ដើម្បីសាងរបៀបតែងជាលំនាំខ្លី ៗ សិន រួចហើយសឹមយើងចាប់សរសេរឲ្យហូរហែតាមលំនាំនោះ ។

## ៤. ដំបូន្មានក្នុងការតែងសេចក្ដី:

ក) ត្រូវធ្វើឲ្យច្បាស់លាស់ គឺធ្វើឲ្យជាប្រយោគខ្លីៗ, ជៀស វាងនូវពាក្យ «ដែល, ដែលជា, ដែលបើជា» ។ល។ ដើម្បី កុំឲ្យធុនត្រចៀកអ្នកស្ដាប់ ។

ខ) ត្រូវធ្វើឲ្យទៅតាមធម្មតា គឺសរសេរពាក្យសាមញ្ញ កុំប្រើពាក្យហួសហេតុពេក ដូចពាក្យថា “សុនខរលាក់ខ្លួនតាមបណ្ដោយវិថី” ...... ត្រូវនិយាយជាសាមញ្ញថា សុនខរត់តាមបណ្ដោយវិថី ” ...... ។

គ) ត្រូវធ្វើឲ្យខែងរ៉ែង គឺត្រូវជៀសវាងពីពាក្យប្រើដែលហើយត្រូវសាងប្រយោគឲ្យមានពាក្យប្លែកពីគ្នា គឺត្រូវចេះប្រើវេវចនៈផ្លាស់ប្ដូរគ្នា ៗ ពិសេសទៅទៀត, ត្រូវចេះប្រើវណ្ណយុត្តិ ដូចជា បុច្ឆនសញ្ញា, សំរេកសញ្ញា ។ល។ ដើម្បីកុំឲ្យរាំខានដល់អ្នកពិនិត្យ ។

## ៥. អំពីវគ្គ

សេចក្ដីដែលគេតែងនីមួយ ៗ តាមធម្មតា ត្រូវចែកចេញជា ៣ វគ្គដូចតទៅ ៖

ក) សេចក្ដីផ្ដើម ( introduction ) ,

ខ) អង្គសេចក្ដី ឬ តួសេចក្ដី (corps du devoir) ,

គ) សេចក្ដីបញ្ចប់, យោបល់ ឬ ការយល់ឃើញ

( conclusion ) ,

ឧបមាថា យើងត្រូវតែងអំពីរបស់ផ្សេងៗ ដែលមាននៅក្នុងបន្ទប់រៀនយើង ។

## សេចក្ដីផ្ដើម:

– ទីកន្លែងបន្ទប់រៀន ។

– របស់ដែលគេឃើញកាលគេចូលទៅក្នុងបន្ទប់រៀន ដូចជា តុសម្រាប់គ្រូ: ឈើកំណាល់, កៅអី; តុសម្រាប់សិស្ស: ចំនួនទទឹងរៀបជារបៀប ។

– របស់សម្រាប់បង្រៀន: ក្ដារខៀន, ផែនទី, កូគោល, ផ្ទាំងគំនូរ នឹងពាក្យសុភាសិត ។ល ។

– របស់សម្រាប់លំអថ្នាក់: ផ្ទាំងរូបភាពផ្សេងៗ, ផ្ទាំងគំនូរផ្សេងៗ ។

## យោបល់:

– របស់ទាំងនេះសុទ្ធសឹងមានប្រយោជន៍ ឬ ល្អមើលនាំឲ្យខ្ញុំបាទមានចិត្តត្រេកត្រអាលនឹងមកកាន់សាលារៀន ។

# ៦. អំពីប្រយោគ

វគ្គនីមួយ ៗ មានប្រយោគជាច្រើន ។ ប្រយោគដែលល្អត្រឹមត្រូវ នោះត្រូវមាន៖

១) ប្រធាន ( sujet ),

២) កិរិយា ( verbe ),

៣) កម្ម ( complément ),

ឧទាហរណ៍: ម្ដាយ បំបៅ ក្មេង ។

ម្ដាយ = ប្រធាន,

បំបៅ = កិរិយា,

ក្មេង = កម្ម;

ពិសេសទៅទៀត, អ្នកនិពន្ធអាចសរសេរផ្ដាសំបូរគ្នាបាន តែនៅមានសេចក្ដីគ្រប់គ្រាន់ជាប្រយោគដដែល ដូចជា:

- បើមិត្តប្រុងនឹងធ្វើដំណើរមក, សូមមិត្តឲ្យដំណឹងខ្ញុំជាមុនសិន ។

គេអាចប្ដូរជា:

— មុននឹងមិត្តធ្វើដំណើរមក , សូមមិត្តឲ្យដំណឹងខ្ញុំសិន ។

។ល។

## ដំបូន្មានពិសេស

មុននឹងតែងសេចក្ដី អ្នកសរសេរគប្បីប្រតិបត្តិតាមដំបូន្មាន ដូចតទៅនេះ ៖

១) ត្រូវអានប្រធានដែលគេដាក់ឲ្យ ពីរ ឬ បីដង រួចកត់បំណាំ ឬគូសសំគាល់ក្រោមសេចក្ដីណា ដែលសំខាន់ៗ ។

២) មុននឹងបណ្ដោយឲ្យស្លាបប៉ាកកាអ្នក រត់លើក្រដាស ត្រូវអ្នកដឹងឲ្យជាក់ នូវរបស់ដែលអ្នកចង់និយាយ ។

៣) ត្រូវព្រាងគោលសេចក្ដីមួយ យ៉ាងខ្លីសិន (Donner le plan) រួចសឹមរៀបរាប់ក្នុងក្រដាសសំណៅ ។

៤) ត្រូវសរសេរឲ្យសមតាមគោលសេចក្ដី មួយវគ្គម្ដងៗ ។

៥) ត្រូវបញ្ចប់ដោយមានយោបល់យ៉ាងខ្លី ដែលជាការ មញ្ជាក់នូវសេចក្ដីតែងទាំងមូល ។

៦) ត្រូវចេះពិនិត្យសាជាថ្មី ដោយសួរខ្លួនឯងថា « តើ យើងសរសេរនេះសមតាមប្រធាន ឬទេ ? »

៧) ត្រូវលុបចោលដោយឥតបង្អង់ នូវពាក្យណា ដែល

ពុំសមរម្យ នឹងប្រយោគណាដែលយើងយល់ថាជាសេចក្ដីពុំត្រូវ នឹងប្រធាន ។

៨) ត្រូវកែពាក្យផ្ទួន ៗ និងលុបចោលនូវសព្ទណាដែលឥតប្រយោជន៍ ។

៩) ត្រូវអានសាជាថ្មីម្ដងទៀត ដើម្បីពិនិត្យកែនូវអក្ខរាវិរុទ្ធ ។

១០) លុះពិនិត្យមើលដឹងថាល្អហើយ សឹមបម្លែងជាសម្រេច ។

## សកម្មភាពក្នុងការតែងសេចក្តី

តាមរបៀបណាយ, ការតែងសេចក្តី ត្រូវវែកញែកពីគ្នា ដោយក្រុម ៗ ដូចតទៅនេះ ៖

ក្រុមទី១. គំរូរូបភាព (Portraits)=សណ្ឋានទ្រង់ទ្រាយនៃមនុស្ស សត្វ ឬវត្ថុអ្វីមួយ ៗ

ក្រុមទី២. ហ្វូងមនុស្សប្រកបការ (Groupe de personnage en action) = ពួកមនុស្សធ្វើកិច្ចការអ្វីមួយ

ក្រុមទី៣. ពិពណ៌នា (Description) =ការសង្កេតអំពីវត្ថុទេសភាព (Observation de choses, de paysages) ៗ

ក្រុមទី៤. សំបុត្រ (Les lettres) = ការទាក់ទងរវាងគ្នានឹងគ្នា ៗ

ក្រុមទី៥. សុភាសិត (Proverbes) =ពាក្យស្លោកប្រដៅផ្សេង ៗ - ពាក្យទំនឹមទំនៀម នឹង ពាក្យបុរាណ ៗ

## គំរូរូបភាព

## ( Portraits )

សេចក្ដីណែនាំ ៖– គំរូរូបភាព គឺជាសណ្ឋាន, ទ្រង់ទ្រាយ ឬ បែបភាពនៃមនុស្ស- សត្វ ឬវត្ថុអ្វីមួយ ដែលគេបានដាក់ឲ្យឃើញពណ៌នាអំពីរូបភាពរបស់មនុស្ស-សត្វ ឬវត្ថុនោះ ៗ

ការធ្វើពិពណ៌នាអំពីរូបភាពនេះ, តាមរបៀបងាយ, គេចែកជាសង្កាត់យ៉ាងនេះ ៖

ក) សណ្ឋានរូបកាយ (Portrait physipue)=ពិពណ៌នាឲ្យសព្វគ្រប់អំពីរូបភាពរបស់មនុស្ស-សត្វឬវត្ថុនោះដូចជា: ដង ខ្នង, ភ្នែក, ច្រមុះ, កំពស់, សម្បុរ, រោម, កន្ទុយ, ជើង, ជាដើម ៗ

ខ) សណ្ឋានចរិយាបថ (Portrait moral) =និយាយអំពីកិរិយា ឫកពា មារយាទរបស់មនុស្ស-សត្វឬវត្ថុនោះដូចជា: កាច, ស្លូត, ត្រង់, ខ្ជិល, ឧស្សាហ៍, ស៊ីច្រើន ឬ ដេកច្រើន ជាដើម ៗ

## ពិពណ៌នាអំពីមនុស្ស

សេចក្ដីណែនាំ ។ – ដើម្បីធ្វើពិពណ៌នាអំពីមនុស្ស, ដំបូងគេធ្វើពិពណ៌នាអំពីរូបរាង បន្ទាប់មក អំពីផ្លូវចិត្តនៃមនុស្សនោះ ។

នៅក្នុងការធ្វើពិពណ៌នាអំពីរូបរាង គេកត់សំគាល់នូវលក្ខណៈណាដែលលេចធ្លុសឡើងជាងគេ ។ រួចទើបគេអធិប្បាយអំពីទឹកមុខ សម្លៀកបំពាក់ និងអាកប្បកិរិយានៃជននោះ ។

នៅក្នុងការធ្វើពិពណ៌នាខាងផ្លូវចិត្ត, គេកំណត់អំពី ចរិតទម្លាប់ – គំនិតឬមារយាទ ។

### គំរូតែងទី ១

ប្រធាន ។– ចូរអ្នកពិពណ៌នា អំពីសិស្សឬសម្លាញ់ម្នាក់ដែលអ្នកធ្លាប់ស្គាល់ច្បាស់ ។

### ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម :

– ទឹកខ្មែរ,

– ពេលដែលបានប្រទះសិស្សនោះ,

២) អង្គសេចក្ដី:

សណ្ឋានរូបរាង

– ខ្លួន, ក្បាល, មុខ, ភ្នែក, សក់ . . .

សណ្ឋានឥរិយាបថ

– ខ្ពិល, ខ្សឹប, ត្រឹមត្រូវ, ល្អ . . .

៣) យោបល់:

– គួរនាំគ្នាយកធ្វើជាគំរូ ព្រោះក្មេងនេះល្អប្រសើរណាស់ ។

## ១. សេចក្ដីអធិប្បាយ

នៅក្នុងបន្ទប់រៀនខ្ញុំ មានមិត្តខ្ញុំម្នាក់ឈ្មោះសម្បត្តិ ។ វាជាក្មេងមានកិរិយាសុភាពត្រឹមត្រូវល្អណាស់ ។ សិស្សដទៃនាំគ្នាស្រឡាញ់រាប់អានវាមិនដែលមានមោះមៃអ្វីឡើយ ។

សម្បត្តិមិត្តខ្ញុំ ប្រកបដោយមាឌធំដំបង វាងពេទន់ក្លួនដូចស្រី សម្បុរសជ្រះ មុខមាត់ស្រស់បស់ប្រិមប្រិយ សមជាអ្នក

មានសីលធម៌ប្រចាំខ្លួន ។ សក់វាខ្មៅរលើប កាត់ខ្លីល្មម ថ្ងាសធំទូលាយ ចិញ្ចើមក្រាស់ ភ្នែកថ្លាខ្មៅ បីដូចជាភ្នែកម្រឹគ ។ ច្រមុះវាវែងស្រួង ហើយងុងបន្តិច ដែលសមទំរង់នឹងរង្វង់មុខមូលរាងពងក្រពើ, មាត់មានរង្វះទូលាយ ជាទីសម្ងំនៅនៃទន្តាសរលើបទាំងពីរជួរលើ-ក្រោម ។ ចង្ការាងស្រួចបុងបន្តិច ថ្គាមចេញគាងល្មម មិនមែនជាថ្គាមខ្លានោះទេ ។ បំពង់កតូចសមសួនដែលតភ្ជាប់មកនឹងដងខ្លួនរៀវស្រាវ, ដៃជើងវែងហើយទន់ល្វត ចង្កេះមូលក្លំ ដូចចង្កេះទេពធីតាក្នុងរូបគំនូរ ដំណើរស្វាហាប់ដូចដំណើរបារាំងខែងរ៉ែង ។ បើគេគន់ពីក្រោយ, ពេលវាដើរ, នោះគេឃើញវាមានភាពសង្ហាត្រកាល សមជាអ្នកតស៊ូហើយក្លាហាន ។

រាល់ព្រឹក, សម្បត្តិភ្ញាក់ពីព្រលឹម លុបលាងខ្លួន ស្លៀកពាក់ស្អាតបាត រួចទៅសាលារៀន ។ វាតែងមកដល់មុនគេបង្អស់ ។ សម្បត្តិបោសសំអាតថ្នាក់រៀន ជូតតុកៅអីគ្រូ នឹងរបស់វា ព្រមទាំងទូពិពិធកណ្ឌសម្រាប់សាលា យ៉ាងស្អាត ។ បើសិនជានៅសល់ពេលខ្លះទៀត មិនទាន់ចូលរៀន វាយកសៀវភៅ

សរសេរដែលជាករណីយកិច្ចគ្រូដាក់ឲ្យវាធ្វើ មកមើលពិនិត្យសាជាថ្មីម្តងទៀត ។ ពុំនោះទេ វាយកសៀវភៅមើលមកអាន ដើម្បីរៀននូវពាក្យស័ព្ទ ។ ជាពិសេស សម្បត្តិតែងទន្ទេញផ្ទួនថែមទៀតនូវមេរៀនណាដែលត្រូវរៀនថ្ងៃនោះ ។ ដោយសារការព្យាយាមនេះ សម្បត្តិក្លាយទៅជាសិស្សមួយរូប រៀនសូត្រពូកែ ល្បីល្បាញជាងគេក្នុងសាលាខ្ញុំ ។ មិនតែប៉ុណ្ណោះ លោកគ្រូណាក៏ដោយតែងស្រឡាញ់វា សរសើរវា ស្ទើរពុំដាច់មាត់ ។ មួយទៀតនៅក្នុងថ្នាក់ វាមិនដែលប្រឡែងគ្នាលេងទេ កាលណាគ្រូពន្យល់វាប្រុងស្តាប់ដោយយកចិត្តទុកដាក់ ។ រីឯមិត្តភក្តិរួមថ្នាក់ជាមួយវាក៏មិនដែលរុកគួនឬបញ្ចេញកិរិយាណាមួយនាំឲ្យវារំខានឡើយ ។

គុណសម្បត្តិល្អ, ថ្លៃថ្នូរ និងកិរិយាសុភាពរាបសានេះ ធ្វើឲ្យសម្បត្តិ ទៅជាឧត្តមសិស្សមួយរូប ដែលយុវសិស្សទាំងឡាយ គប្បីយកតម្រាប់តាម ។

**តំរូតែងទី ២**

ប្រធាន.– ចូរអ្នកធ្វើពិពណ៌នា អំពីជាងដែក ដែលអ្នកបានស្គាល់ ហើយរៀបរាប់អំពីចលនាដែលគាត់បានធ្វើក្នុងពេលដែលអ្នកឃើញ ។

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម :

– ហេតុដែលនាំឲ្យអ្នកទៅកាន់រោងជាងដែក ។

២) អង្គសេចក្ដី :

– ពិពណ៌នាអំពីរូបរាង សំលៀកបំពាក់របស់គាត់ ។

– ពិពណ៌នាអំពីចលនា និងអាកប្បកិរិយារបស់គាត់ ។

– ថ្ងៃងំអំពីចរិតរបស់គាត់ ។

៣) សេចក្ដីបញ្ចប់ :

– អ្នកស្រឡាញ់ចូលចិត្តគាត់ ហើយសរសើរគាត់ ព្រោះគាត់ជាមនុស្សពូកែធ្វើការងារ និងស្លូតត្រង់ចំពោះគេ...

# ១. សេចក្ដីអធិប្បាយ

កាលពីថ្ងៃព្រហស្បតិ៍មុន បិតានាងខ្ញុំបានប្រើនាងខ្ញុំឲ្យយកកាំបិតមួយទៅជួល ពូសំ ច្រុងមុខឡើងវិញឲ្យមុត ព្រោះកាំបិតនោះឆែបមុខអស់ជាច្រើនអន្លើទៅហើយ ។ នាងខ្ញុំក៏យកកាំបិតដើរតម្រង់ទៅពេងជាង ពូសំ ដែលតាំងនៅចម្ងាយប្រហែលមួយគីឡូម៉ែត្រអំពីខាងត្បូងផ្ទះនាងខ្ញុំ ។

ពូសំ ស្គាល់នាងខ្ញុំយ៉ាងជិតដិត ព្រោះគាត់នៅក្នុងភូមិជាមួយគ្នា ហើយធ្លាប់ប្រស្រ័យទាក់ទងជាមួយមាតាបិតានាងខ្ញុំជាញឹកញាប់ផង ។ គាត់មានមាឌធំដំបង មុខបែបធ្អឹង អាយុប្រមាណ ៤០ ឆ្នាំ ។ គាត់លែងខ្លួនទទេ បង្ហាញឲ្យឃើញសាច់ដុំលេចឡើងតាមដើមដៃ, កំភួនដៃ, ទ្រូង, ខ្នង, និងដំធារពោះ មើលទៅគួរឲ្យខ្លាចកម្លាំងគាត់យ៉ាងក្រៃលែង ព្រោះនៅពេលដែលគាត់លើកដៃម្ដង ៗ សាច់ដុំទាំងនេះរត់រស់រវើកឡើងម៉ាន់ ៗ ណែន ៗ សព្វកន្លែងទាំងអស់ ។ ដោយសារគាត់ប្រើដៃស្ដាំលើកញញួរធ្ងន់ជានិច្ចជាកាល ស្មាស្ដាំគាត់ឡើងពូន

ខ្ពស់ផាន់ស្នាធ្មេង ៗ ភ្នែកទាំងគូរបស់គាត់ឡើងក្រហម ដោយសារផ្សែងហុយចូល និងដោយសារកំដៅភ្លើង ៗ

គាត់ស្លៀកតែខោខ្លីមួយ ហើយយកកំណាត់បាវបាំងពីមុខ ដើម្បីចៀសវាងកុំឲ្យផ្កាភ្លើងខ្ទាតមកត្រូវឆេះខោ និងរលាកសាច់គាត់ ៗ គាត់ពាក់ស្បែកជើងឈើ ប្រយោជន៍ការពារកុំឲ្យភ្លើងរលាកបាតជើងគាត់ ៗ

ពូសំ ធ្វើការក្រោមម្លប់រោងដោលមួយ ប្រក់ស្លឹក ដែលមានពិតានខ្ពង់ទឹត ព្រោះផ្សែងភ្លើងកាន់ ៗ

បន្ទាប់ពីការនិយាយថ្លៃឈ្នួលរួចហើយ គាត់ដោះផ្លែកាំបិតចេញពីដង ហើយចាប់ផ្លែកាំបិតនោះដោយដង្កាប់ដែកដងវែង ដាក់បង្កប់ទៅក្នុងគំនរធ្យូងតូច ៗ ក្នុងជើងក្រាន ៗ រួចគាត់បង្គាប់ឲ្យក្មេងបម្រើដំទង់ រវៃស្នប់សម័យថ្មីធ្វើអំពីដែក ដែលដាក់បន្តក្ដាប់ពីខាងក្រោយជើងក្រាន ៗ កាលណាដែកឡើងក្រហមហើយ គាត់ធ្វើសញ្ញាឲ្យឈប់រវៃ រួចគាត់យកដង្កាប់ចាប់ដុំដែកនោះដោយដៃខាងធ្វេង ដាក់លើដែកទ្រនាប់ ហើយដៃស្តាំគាត់ចាប់

ញញួរដ៏យ៉ាងញាប់ដោយប្រែត្រឡប់ចុះឡើង - ចុះឡើង ៗ ផ្កាភ្លើងខ្ចាតយ៉ាងព្រោងព្រាតទៅគ្រប់ទិសទី ប៉ុន្ដែគួរឲ្យឆ្ងល់ណាស់ខាងខ្លួនគាត់មិនខ្ចាតមកសោះឡើយ ៗ

ពូដាំងនេះ ប្រសប់ណាស់ ព្រោះគាត់ដុតផ្លែកាំបិតនាងខ្ញុំតែមួយដង យកមកដំហើយបានសម្រេចការ ៗ មុននឹងជ្រលក់ផ្លែកាំបិតនោះទៅក្នុងទឹក គាត់លើកដុំដែក ដែលប្រែទៅជាពណ៌ខ្មៅដូចដើមវិញនោះ ជូនមកនាងខ្ញុំ ធ្វើឲ្យខ្ញុំស្ទុះថយក្រោយព្រមទាំងស្រែកភ្ញាក់សំឡេងផង ហើយគាត់សើចធ្វើព្រងើយ ៗ

ពូសំ ជាកម្មករមួយរូប សង្វាតធ្វើការណាស់ ៗ ស្នាដៃដែលគាត់ស្ថាបនាទាំងប៉ុន្មាន សុទ្ធតែជាប់លាប់ហើយមុតល្អជាទីបំផុត ៗ ជាពិសេស, គាត់ប្រើសេចក្ដីគួរសមយ៉ាងពក់ទាក់ក្រៃលែងចំពោះភ្ញៀវដែលមកទាក់ទងជាមួយគាត់ ៗ

អាស្រ័យហេតុនេះហើយ បានជាអ្នកស្រុកនៅក្នុងភូមិនាងខ្ញុំស្រឡាញ់រាប់អានគាត់ នាំគ្នាយកការមកឲ្យគាត់ធ្វើមូលគ្នាទាំងអស់ ៗ គាត់ទទួលលទ្ធផលជាប្រាក់ផង ជាសេចក្ដីសរសើរ

ផង ដែលជាហេតុធ្វើឲ្យគាត់រស់នៅក្នុងបរិយាកាសយ៉ាងសែនមនោរម្យ ៗ

## ករណីយកិច្ចទី ១

ប្រធាន ៖— ចូរអ្នកធ្វើពិពណ៌នា អំពីអ្នកអារឈើហុបម្នាក់ ដែលអ្នកបានឃើញច្បាស់ ៗ

### គោលសេចក្ដី

( Plan )

១ ) សេចក្ដីផ្ដើម :

— កន្លែងដែលអ្នកបានឃើញអ្នកអារឈើធ្វើការ ៗ

២ ) អង្គសេចក្ដី :

— ពិពណ៌នាអំពីទឹកមុខ សំលៀកបំពាក់របស់គាត់ ៗ

— កិច្ចការរបស់អ្នកអារឈើ ៖

ក ) គេដាក់ឈើដូចម្ដេច ដើម្បីនឹងអារឲ្យត្រង់ ?

— ដឹកបន្ទាត់ ៗ

ខ) គេឈររបៀបណាដើម្បីធ្វើការ ។

គ) រណារចុះឡើងៗ ហើយបញ្ចេញសូរបែបណា ?
គេលាបមុខរណារនឹងអ្វី ដើម្បីកុំឲ្យស្អិត ?

ឃ) សេចក្ដីប្រឹងប្រែងយ៉ាងធន់ទ្រាំ ហើយវាធ្វើឲ្យចុកដៃ ចុកជើង ឈឺចង្កេះពេញខ្លួន និងឆ្អឹងដើមទ្រូងជាដើម

៣) សេចក្ដីបញ្ចប់ :

ផលប្រយោជន៍ នៃការអារឈើនេះ អាចឲ្យគេស្ថាបនាជាគ្រឹះស្ថានធំៗ យ៉ាងទំនើប និងឲ្យសុខភាពដល់មនុស្ស ។ ប៉ុន្តែ ក្នុងសម័យបច្ចុប្បន្ននេះ ការអារឈើដោយគ្រឿងយន្តរឹតតែកើតមានច្រើនហើយ ដែលជាសកម្មភាពមួយ អាចជួយសម្រាលកម្លាំងមនុស្ស បានដោយសេរី ។

## ពិពណ៌នាអំពីសត្វ

សេចក្ដីណែនាំ ៖— ការធ្វើពិពណ៌នាអំពីសត្វ ក៏ដូចជាការធ្វើពិពណ៌នាអំពីមនុស្សដែរគឺ ៖

ដំបូងយើងត្រូវពណ៌នាអំពីទំហំភាពទូទៅ ( កំពស់ - រាង - ពណ៌សម្បុរ ) បន្ទាប់មកគប្បីពណ៌នាអំពីចំណែកខ្លួនផ្សេងៗ ដោយអធិប្បាយលើចំណែកណា ដែលប្លែកខុសពីគេ ដូចជាស្នែងក្របី, ប្រមោយដំរី ទឹកមុខនៃសត្វឆ្កែ ជាដើម ។

ក៏ប៉ុន្តែ សត្វពុំមែននៅនឹងមួយកន្លែងឡើយ ដូច្នេះ ប្រូវអ្នកអធិប្បាយអំពីកាយវិការ - អាកប្បកិរិយា - សម្រែក និងរបៀបជីវភាពរបស់វា ។

គោលសំខាន់មួយទៀត ប្រូវអ្នកកុំភ្លេចអធិប្បាយអំពីគុណសម្បត្តិ ឬគុណវិបត្តិ របស់វាឲ្យសោះ ។

ជាទីបញ្ចប់ ត្រូវអ្នកបញ្ចេញមនោសញ្ចេតនារបស់អ្នកចំពោះសត្វនោះ ។

## គំរូតែង ទី ៣

ប្រធាន .– ចូរអ្នកអធិប្បាយអំពីគោមួយដែលអ្នកបានឃើញច្បាស់ ព្រមទាំងអធិប្បាយអំពីប្រយោជន៍របស់សត្វនេះផង

### ក· ការរៀបចំ

អ្នកបានឃើញគោនោះនៅទីណា ? តូចឬធំ ? សម្បុរអ្វី ? ខ្លួនវាមានសណ្ឋានដូចម្ដេច ? ធាត់ឬស្គម ? កំពុងឬស្ដើង កវាបែបណា ? ទ្រគាកដូចម្ដេច ? កន្ទុយនឹងជើងយ៉ាងម៉េច ? ក្បាលវាតូចឬធំ ? ក្អែក, ត្រចៀក, ស្នែង, មាត់, ថ្គាម, ច្រមុះ មានលក្ខណៈយ៉ាងណា ? គេធ្វើដូចម្ដេច ដើម្បីនឹងដឹកវាឲ្យបានស្រួល ? ដំណើរវាដូចម្ដេច ? វាជាសត្វកាចឬស្លូត ? មានអំណាត់ឬទេ ? វាផ្ដល់ប្រយោជន៍អ្វីដល់យើងខ្លះ ពេលវារស់នៅ នឹងពេលវាស្លាប់ទៅ ? ស្បែក, ឆ្អឹង, ស្នែង, វាមានប្រយោជន៍យ៉ាងណា ?

ទីបំផុត ចូរអ្នកបង្ហាញឲ្យឃើញថា គោជាសត្វជំនួយមួយយ៉ាងសំខាន់ដល់កសិករ ។

## ១. គោលសេចក្តី

១) សេចក្តីផ្តើម :

– ទីកន្លែងនិងពេលដែលអ្នកបានឃើញ,

២) អង្គសេចក្តី :

សណ្ឋានរូបរាង

– មាឌ, ពណ៌, សម្បុរ, រោម . . .

សណ្ឋានឥរិយាបទ

– ស្គម, កាច, ខ្ជិល, ស្វាហាប់ . . .

៣) យោបល់ :

– គោជាសត្វស្រុក អាចផ្តល់ប្រយោជន៍ ដល់ជនកសិករយ៉ាងប្រសើរ ។

## គ. សេចក្តីអធិប្បាយ

ថ្ងៃអាទិត្យមួយ, នៅពេលដែលព្រះអាទិត្យកំពុងរោយកំទេចរស្មីយ៉ាងក្តៅ ខ្ញុំបានចោលក្អែកទៅកើតឃើញគោមួយ ដែលពួសៅម្ចាស់វាទើបនឹងលាងទឹករួច ហើយដឹកយកមកចងក្រោម

ម្ប់ដើមស្វាយជិតផ្ទះខ្ញុំបាទ ។

គោនោះឈ្មោលនៅជំទង់ វាធំមាំ កំពស់ប្រមាណមួយ ម៉ែត្រសាមសិប ដងខ្លួនវែងល្មម តែបែបអើតមុខបន្តិច ហើយ រីកកំប៉ោងត្រង់ប៉េង ។ វាមានសម្បុរប្រផេះក្រមៅ ទើបបានឲ្ សៅរ៍ឲ្យឈ្មោះវាថា អាត្នោត ។

តពីដងខ្លួនទៅមុខ មានកមួយយ៉ាងមាំសម្រាប់អូសរទេះ ឬ នង្គ័ល សឹងមានរោមសកកខ្វិលពីខាងលើ ។ នៅក្រោមកមាន បន្ទះស្បែកប្រហែលមួយដេស៊ីម៉ែត្រធ្លាក់យារស្តូតចុះមក ជិតដល ចន្លោះជើងមុខទាំងពីរដែលគេហៅថាប្លួរ ។ តពីក គឺក្បាល ដែលមានមុខច្រួបួញៗហើយវែង ស្នែងទាំងពីរដុះពីលើ ដែល មានចុងខុបស្មើរតែជួបចូលគ្នា ។ ភ្នែកវាមូលប៉ុនស៊ុតទា ពណ៌ ខ្មៅព្រីកដូចត្បូងនិល, ត្រចៀកធំក្រឡួចរួមរាងស្លឹកម្លូ, ច្រមុះធំខ្ មានទឹកសើមរលេរតុំដែលជាប់ ។

ប៉ែកខាងក្រោយ មានកន្ទុយមួយទំហំជិតប៉ុនកដៃ វា រៀវខាងចុង ប្រកបដោយរោមវែងៗសរសៃធំៗមួយកញ្ចុំនៅ

បំផុត ៗ វាប្រើកន្ទុយនេះ សម្រាប់ដេញសត្វល្អិត ៗ ដែលមកយាយីវា ។ ចំណែកជើងវាទាំងបួន មាំ ៗ ហើយឡើងសាច់ដុំសាច់រើកសព្វកន្លែង ដែលជាហេតុឲ្យគេសំគាល់បានថា សត្វនេះដើរបានឆ្ងាយណាស់ , ចុងជើងមានម្រាមពីរជំមានក្រចកមូលក្រឡូម ៗ

ពេលនោះ វាកំពុងកើចស្មៅចេញពីជាល ដែលម្ចាស់ប្រុតមកដាក់ទុកឲ្យទទួលទាន ។ បបូរមាត់យ៉ាងសើមរលររបស់វាកំរើកឡើងធ្វើឲ្យឃើញថ្គាមខាងលើឥតមានធ្មេញសោះ ។

ដើម្បីនឹងដឹកវាឲ្យបានស្រួល គេចុះច្រមុះវាដោតខ្សែចងពន្ធទៅលើក្បាលពីខាងក្រោយស្នែង រួចចងខ្សែមួយយ៉ាងវែងសម្រាប់ដឹក ៗ គោជាសត្វមួយមានដំណើររហ័សរហួនជាងក្របីថែមទាំងធន់នឹងក្ដៅបានលើសក្របីទៀតផង ។

អាត្មាត គោពូសោរ៍ជាសត្វស្លូត ទុកជាក្មេងទៅប្រឡែងលេងក៏ដោយ ក៏វាមិនរវល់នឹងដេញ ឬគ្រវីគ្រវាត់ស្នែងរកបុះឡើយ ចំពោះការងារវិញ ក៏វាមិនដែលរួញរាទេ ទោះជាលំបាកយ៉ាង

ណា ក៏វាស៊ូទ្រាំឲ្យទាល់តែហើយ ។ ពេលបរិភោគសោតទៀត វាពុំដែលទៅបបិចបប៉ោចស៊ីដំណាំដាំដុះរបស់អ្នកជិតខាង នាំឲ្យសៅហ្មងឡើយ ។ វាបរិភោគតែវត្ថុណាដែលម្ចាស់វាបានឲ្យ ។

គោជាសត្វពាហនៈមួយ ដែលមានប្រយោជន៍យ៉ាងសំខាន់បំផុតសម្រាប់មនុស្ស ទាំងកាលវានៅរស់ទាំងដល់ពេលវាស្លាប់ទៅ ។ ពួកកសិករពុំអាចបោះបង់សត្វបម្រើដ៏វិសេសនេះបានឡើយ ។ គឺគោនេះឯងហើយដែលទាញនង្គ័ល, រនាស់ឬអូសរទេះដឹកនាំសម្ភារវត្ថុផ្សេង ៗ ដែលមនុស្សត្រូវការ ។

ក្នុងកិច្ចការខាងស្រែ វាជួយកម្លាំងយើង តាំងតែពីពេលភ្ជួរ-រាស់-ដឹកស្រូវពូជ-ជញ្ជូនសន្ទូងទៅស្ទូង រហូតដល់ពេលច្រូតកាត់ដឹកកណ្ដាប់ទៅបោកបែនឬបញ្ជាន់នៅទីលាន រួចហើយជញ្ជូនស្រូវយកមកទុកក្នុងជង្រុក ។

លុះវាស្លាប់ទៅ វាផ្ដល់នូវសាច់ដ៏មានឱជារសយ៉ាងក្រៃលែងសម្រាប់ធ្វើម្ហូបទទួលទានក្នុងពេលភ្លាម ៗ ក៏បាន នឹងធ្វើងៀតទុកអាស្រ័យទៅថ្ងៃមុខក៏បាន ។ គេយកស្បែកវាមកសម្រាប់ធ្វើ

ជាកាកតាប-ស្បែកជើង-កាបូបតូច-ធំ- ខ្សែក្រវ៉ាត់ ទំនិវត្ថុនានាទៀតជាច្រើន ។ ចំណែកស្នែងរបស់វា គេយកមកធ្វើជាក្រាសសិតសក់, ដងកណ្ដៀវ, ដងប៉ាកកា, ដងកាំបិតឬគ្រឿងប្រើប្រាស់ផ្សេងៗ ។

## គំរូតែងទី ៤

ប្រធាន. – ចូរអ្នកអធិប្បាយអំពីឆ្មាមួយ ដែលអ្នកបានចិញ្ចឹម ។

### ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម:

– ពេល,

– កន្លែងដែលឃើញ ។

២) អង្គសេចក្ដី:

សណ្ឋានរូបរាង

- ក្បាល, ប្រមុះ, ដងខ្លួន, កន្ទុយ ...

សណ្ឋានឥរិយាបថ

- ស្ទួត, កាច, ប្រសប់, ឧស្សាហ៍ ...

៣) យោបល់ :

- វាមានគុណសម្បត្តិប្រសើរ ចេះចាប់កណ្តុរដែលកាត់ខោអាវយើង ហើយចេះប្រឡែងលេងនឹងកូនក្មេងទៀតផង ។ គួរឲ្យយើងទំនុកបំរុងវា ។

## ១. សេចក្តីអធិប្បាយ

ខ្ញុំបានចិញ្ចឹមឆ្មាឈ្មោលមួយ ដែលគ្រួសារខ្ញុំបានឲ្យឈ្មោះវាថា: « អាសម្បត្តិ » ។ បានជាឲ្យឈ្មោះដូច្នេះ ព្រោះអ្នកទាំងអស់គ្នាមានបំណងនឹងឲ្យវាថែរក្សាសម្បត្តិទ្រព្យឲ្យបានគង់វង់ ។

អាសម្បត្តិឆ្មាខ្ញុំ មានកំពស់ប្រហែលម្ភៃសង្ទីម៉ែត្រ និងបណ្តោយខ្លួនប្រហែលសាមសិបសង្ទីម៉ែត្រ សម្បុរគ្រសក់លាយពណ៌លឿងកាត់ដាកង់ៗ ស្រដៀងខ្លាត្រី ។ មុខវាឡើង

ក្រមាម-មាម ដូចជាខ្លា យ៉ាងកំណាច លើបបូរមាត់ខាងលើ មាន ពុកមាត់ ប្រាំមួយ-ប្រាំពីរសរសៃវែងៗ ។ រង្វះមាត់ខុបចុះក្រោម, ពេលណាវាហាឡើងម្ដងៗ ចង្កូមទាំងសងខាង ចេញមកបង្ហាញ អ្នកផង គួរឲ្យយល់ថា សត្វនេះកាចសាហាវណាស់ ។ ក្រែកវាទាំងពីរធំៗ ហើយភ្លឺថ្លា តែពងពណ៌លឿងបន្តិច ។ ត្រចៀកខ្លី ធំក្រោមស្រួចលើ អាចបត់ឬ បិទបើកបាន ក្នុងពេលវាត្រូវសូរ ឮប្លែក ៗ ជើងវាទាំងបួនប្រកបដោយសាច់ដុំយ៉ាងរស់រវើកសព្វ កន្លែង ចុងម្រាមនីមួយ ៗ មានក្រចកយ៉ាងវែង ដែលជាអាវុធ យ៉ាងសំខាន់សម្រាប់ប្រយុទ្ធនឹងបច្ចាមិត្ត ។ អាសម្បត្តិមានកន្ទុយ ខ្វៀនៈពេលណាវាមកជិតខ្ញុំ វាធ្វើកន្ទុយវា ង៉ិតង៉ុត-ង៉ិតង៉ុត ។

ឆ្មាខ្ញុំមានកិរិយាល្អណាស់ វាមិនឥតរបប ទៅលួចស៊ីម្ហូប ម្ហាណាដែលគេមិនបានឲ្យវានោះទេ ។ ពេលគ្រួសារខ្ញុំបរិភោគ អាហារ វាដើរមកជិតហើយអង្គុយងើបក្បាលមើលអ្នកនេះបន្តិចអ្នក នោះបន្តិច មួយសន្ទុះទើបវាក្រាបកំប្រោនទៀបនោះ ហើយស្រែក ម៉េវៗ ជាសញ្ញាឲ្យគេដឹងថា វាសុំម្ហូបម្ហាទាំងនោះទទួលទានផង

ប៉ុន្តែគ្រួសារខ្ញុំមិនដែលបោះដុំម្ហូបអ្វីឲ្យវាទេ ព្រោះកុំឲ្យវាធ្លាប់ទៅជាឆ្កែខូចបាន លុះណាតែបរិភោគរួច ទើបបានដាក់បាយឲ្យវាអាស្រ័យ ។ វាសោតក៏មិនសូវមករវិចរវាម ដែលជាហេតុឲ្យគេរំខានសោះឡើយ បើវាមកដិត វាក្រាបនៅស្ងៀមតែម្ដង ។ ពេលរាត្រី អាសម្បត្តិ មិនសូវដេកលក់យូរទេ វាដើរចប្រប់អារ៉ប់សព្វកន្លែងក្នុងផ្ទះ ដើម្បីយាមល្បាតទឹងចាំលបខាំកណ្ដុរណា ដែលកកេរឬកាត់អីវ៉ាន់ ។ ក្នុងវេលាថ្ងៃ ពេលគេទៅធ្វើការអស់ បើសិនជាម្ដាយខ្ញុំហាលត្រីឬសាច់នៅកណ្ដាលវានហាល អាសម្បត្តិតែងទៅដេកចាំយាមល្បាតនៅក្បែរនោះ ក្រែងជួនមានសត្វចង្រៃ ឬឆ្មាមករកឆាបឆក់យកទៅស៊ី វាទឹងស្ទុះទៅសង្គ្រប់ខាំដើម្បីការពារ ។

ដោយសារមារយាទគួរឲ្យស្រឡាញ់យ៉ាងនេះ ទើបបានជាគ្រួសារខ្ញុំតែងមេត្តាដល់វា ហើយទំនុកបំរុងវាដូចជាសាច់ញាតិម្នាក់នៅរួមគ្រួសារជាមួយ ។

## ពិពណ៌នាអំពីវត្ថុ

សេចក្ដីណែនាំ —មុននឹងធ្វើពិពណ៌នា ចូរអ្នកសង្កេតពិនិត្យនូវវត្ថុនោះឲ្យហ្មត់ចត់មែនទែនសិន ដើម្បីឲ្យបានដឹងនឹងស្គាល់យ៉ាងច្បាស់លាស់ ។

យើងអាចស្គាល់ទ្រង់ទ្រាយ, ទំហំ, ពណ៌ ដោយសារវិញ្ញាណរបស់យើង,

យើងអាចដឹងថា របស់នេះរលីង ឬគគ្រាតដោយបាតដៃ,

ដោយសារច្រមុះ យើងអាចធុំក្លិន,

ដោយសារត្រចៀក យើងអាចឮសូរសម្លេងផ្សេង ៗ ។

ហេតុនេះ ក្នុងការធ្វើពិពណ៌នាអំពីវត្ថុ អ្នកត្រូវកំណត់ដូចតទៅ ៖

១) អស់ទាំងរបស់ដែលអ្នកមើលឃើញ,

២) អស់ទាំងសម្លេងដែលអ្នកស្ដាប់ឮ,

៣) អស់ទាំងក្លិនដែលអ្នកធុំ បើសិនជាមាន ។

មួយវិញទៀត ចូរអ្នកកុំភ្លេចបញ្ចេញមនោសញ្ចេតនារបស់អ្នកចំពោះវត្ថុនោះ ។

នៅទីបញ្ចប់ អ្នកត្រូវរំលឹកអំពីផលប្រយោជន៍ នឹងអំពីការថែរក្សា វត្ថុនោះឲ្យបានគង់វង់ ដើម្បីប្រើការបានជាប់លាប់ជាស្ថាពរតទៅ ។

គំរូតែងទី ៥

ប្រធាន.- អ្នកបានទិញកាំបិតបត់មួយ សម្រាប់ប្រើការ ចូរអ្នកធ្វើពិពណ៌នាអំពីកាំបិតនោះ ។

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម:

- ទីកន្លែង
- ពេល ដែលអ្នកបានទិញ ។

២) អង្គសេចក្ដី:

- ការធ្វើពិពណ៌នាអំពីផ្លែ,
- ការធ្វើពិពណ៌នាអំពីដង,

– ប្រយោជន៍របស់កាំបិតនោះ ។

៣ ) សេចក្តីបញ្ចប់ :

## ១. សេចក្តីអធិប្បាយ

ល្ងាចថ្ងៃអាទិត្យមួយ មុនបវេសនកាលប្រមាណបួនថ្ងៃ ខ្ញុំបាទបានទិញកាំបិតបត់មួយ ដើម្បីយកមកប្រើប្រាស់ក្នុងគ្រឿងឧបករណ៍នៃការសិក្សា ។

កាំបិតនោះមានពីរចំណែក គឺផ្លែនឹងដង ។ ផ្លែវាភ្លឺរលោងអាចឆ្លុះមុខបាន រាងបួនជ្រុងទ្រវែង ស្រួចចុង ដែលគេធ្វើអំពីបន្ទះដែកថែបយ៉ាងល្អ ។ ប៉ែកខាងលើនៃផ្លែ មានកម្រាស់ប្រមាណពីរមិល្លីម៉ែត្រ គឺជាខ្នងកាំបិត ។ ប៉ែកខាងក្រោមរៀវស្តើងហើយមុតយ៉ាងក្រៃលែង គឺជាមុខកាំបិត ។ ត្រង់ក្បែរខ្នងកាំបិត មានចង្អូរមួយប្រវែងមួយសង្ទីម៉ែត្រ ដែលអាចឲ្យគេបើកបិទបានដោយងាយ ។ នៅខាងចុងផ្លែមានចំឡាក់សត្វឆ្កែមួយពោល គឺជាត្រាសំគាល់របស់ហាងធ្វើកាំបិតនេះ ។

ដងក៏ធ្វើអំពីដែកសដែរ ដែលជាបន្ទះដែកពីរផ្ទាំងតូច ៗ មាន

ស្នាមឆ្កូតប៉ោង១ ។ នៅខាងគល់ដង មានក្រវិលស្ពាន់មួយ សម្រាប់ដាក់ខ្សែបង ។

កាំបិតនេះជាអ្នកឧបត្ថម្ភខ្ញុំបាទពាល់ថ្ងៃ ក្នុងកិច្ចសិក្សា ។ ខ្ញុំបាទចិតខ្មៅដៃ និងកោសលុបអក្សរយ៉ាងស្អាត ដោយសារវា ។ នៅពេលធ្វើហត្ថកម្មង ។ កាំបិតនេះឯងជាអ្នកសំអាតក្រដាស ពណ៌ ទឹងឫស្សី ឬវត្ថុផ្សេងៗទៀត ។ ក្រចកដៃក្តី ក្រចកជើងក្តី វាសំអាតយ៉ាងសមរម្យ ។ មិត្តភក្តិខ្ញុំបាទជាច្រើនគ្នាក៏ទាញ អត្ថប្រយោជន៍អំពីកាំបិតនេះដែរ ។

ខ្ញុំបាទខំថែរក្សាកាំបិតបត់ត្រាក្កែរបស់ខ្ញុំបាទនេះ ឲ្យបានគង វង់ស្ថិតស្ថេរ ដែលជាបាតុកម្មនៃគំនិតសន្សំសំចៃរបស់ខ្ញុំបាទ ។

គំរូតែងទី ៦

ប្រធាន .– ចូរអ្នកធ្វើពិពណ៌នាពីភូមិកំណើតរបស់អ្ន ហើយពន្យល់ឲ្យឃើញច្បាស់លាស់ថា ហេតុអ្វីបានជាអ្នកស្រ ឡាញ់ដីមួយដុំនេះម៉្លេះ ? (វិញ្ញាបនប័ត្រ ឆ្នាំ ១៩៥៥

# ក. គោលសេចក្តី

១) សេចក្តីផ្តើម :

- ទីកន្លែងនៃភូមិនោះ ;

២) អង្គសេចក្តី :

- សភាពមើលឃើញពីនាយ ,
- របៀបភូមិនោះ ;

៣) សេចក្តីបញ្ចប់ :

- ការនឹកឃើញអំពីភូមិនោះ ។

# ខ. សេចក្តីអធិប្បាយ

ភូមិកំណើតរបស់ខ្ញុំ ស្ថិតនៅតាមបណ្តោយដងស្ទឹងសង្កែ មានឈ្មោះថា " ភូមិព្រែកក្រូប " ។ ភូមិនេះមិនសូវមានសភាពអ៊ូអរប៉ុន្មានទេ មានផ្ទះប្រក់ក្បឿងខ្លះ ប្រក់ស្លឹកខ្លះ ប្រមាណម្ភៃ ច្វាយផ្ទះ សង់ជ្រកនៅក្រោមដើមឈើផ្លែធំ ៗ ដ៏មានម្លប់ត្រជាក់ត្រឈឹងត្រឈៃ គួរជាទីមនោរម្យយ៉ាងក្រៃលែង ។

នៅជុំវិញភូមិនេះ មានដើមដូង- ស្វាទីង ស្វាយដុះដៃគ្នា

ជាផ្លូវហាក់ដូចជារបងយ៉ាងមាំសម្រាប់ការពារអន្តរាយផ្សេង ៗ ។ ពេលព្រលឹមស្វាងកាលណា ភូមិនេះមានសភាពរញ្ជើបរញ្ជួលអ៊ូអរដូចជាកូនផ្សារតូចមួយដែរ ដោយអ្នកនៅក្នុងភូមិ ជាកសិករខ្លះ ជាអ្នកលក់ដូរខ្លះ ។ កសិករនាំគ្នាដឹកគោ-ក្របី ឬ បររទេះចេញទៅប្រកបការងារវាលស្រែ, អ្នកលក់ដូរ ទូលកញ្ជើ-ល្អី រែកពុន ចេញទៅលក់ដូរឯផ្សារខ្ពប នៅសល់តែក្មេងតូច ៗ តាចាស់នឹងមនុស្សស្រីខ្លះ ដែលមានភារៈត្រូវបំពេញនឹងផ្ទះ ។ ដល់វេលាល្ងាចត្រជាក់ ទើបជនអ្នកប្រកបការ ត្រឡប់មកកាន់គេហដ្ឋានវិញ ។

នៅក្នុងភូមិនេះ មានវត្តមួយឈ្មោះ " វត្តព្រែកក្រូច " សម្រាប់ឲ្យពួកពុទ្ធបរិស័ទ នាំគ្នាទៅធ្វើបុណ្យបំពេញកុសលដើម្បីយកផលទៅបរលោក ។

អ្នកភូមិទាំងអស់គ្នា មានចិត្តស្រឡាញ់រាប់អានគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ។ បើអ្នកណាមួយមានកិច្ចរវល់ គេតែងនាំគ្នាទៅជួយរហូតដល់សម្រេចកិច្ចធុរៈនោះ ។ នេះបញ្ជាក់ថា

អ្នកភូមិខ្ញុំបាទនេះ មានទឹកចិត្តសាមគ្គីរវាងគ្នានឹងគ្នា ពុំប្រកាន់ថាអ្នកកន្ទៀត ឬ សាច់ញាតិឡើយ ។ សេចក្ដីសាមគ្គីនេះឯង អាចជួយជនម្នាក់ៗ ឲ្យសម្រេចកិច្ចរវល់ផ្ទាល់ខ្លួនផង ព្រមទាំងអាចបានជាកម្លាំងយ៉ាងមាំខាងកិច្ចការពារសន្តិសុខក្នុងភូមិផង ។ ខ្ញុំបាទក្ដី មិត្តភក្ដិខ្ញុំបាទក្ដី ដែលទៅនៅរៀនសូត្រទីក្រុង លុះត្រឡប់ចូលទៅលេងក្នុងភូមិម្ដងៗ អ្នកភូមិទាំងប្រុសទាំងស្រី តែងមកជួបជុំ ចចាកអាក៉កសួរសុខ-ទុក្ខ សំដែងនូវទឹកចិត្តភក្ដីយ៉ាងជ្រាលជ្រៅ ។ ដោយសារការស្រឡាញ់រាប់រកគ្នាឥតមោះមៃនេះឯងហើយ ទើបបានជាគ្រួសារខ្ញុំបាទ រស់នៅដោយសេចក្ដីសុខក្សេមក្សាន្ត ។

ខ្ញុំបាទស្រឡាញ់ភូមិកំណើតរបស់ខ្ញុំបាទណាស់ ព្រោះជាកន្លែងដែលចេះអប់រំខ្ញុំបាទឲ្យចេះស្រឡាញ់ជនជាតិផងគ្នា ដោយចិត្តភក្ដី ។

## ហ្វូងមនុស្ស

សេចក្តីណែនាំ .— ការរៀបរាប់អំពីហ្វូងមនុស្ស ជាកិច្ចការមួយដែលយើង ត្រូវសរសេររៀបរាប់បញ្ជាក់ អំពីសភាពគួរអរដែលមនុស្សទាំងនោះនៅជួបជុំគ្នា ។ បន្ទាប់មក យើងត្រូវសរសេរអំពីកាយវិការ គឺកិរិយាបុកគារបស់មនុស្សទាំងអស់នោះ ឲ្យឃើញជាក់ច្បាស់ហើយឲ្យកំរើកជានិច្ច ( Faites mouvoir vos personnages ) ។

ទីបំផុត យើងត្រូវចាំឲ្យជាក់ថា ការសរសេរពីហ្វូងមនុស្ស យើងមិនបាច់រៀបរាប់ពីរូបមនុស្សម្នាក់ៗ ឲ្យហួសហេតុទេ គឺគ្រាន់តែជ្រើសរើសលំនាំសំខាន់ៗខ្លះ មកពណ៌នាបានហើយ រួចគេបញ្ចប់ការតែងដោយបញ្ចេញការចាប់អារម្មណ៍ឬយោបល់របស់ខ្លួន ។

### គំរូតែងទី ៧

ប្រធាន .— មនុស្សមួយហ្វូងកំពុងជួសជុលវិថីមួយដែល

ខូចខាតដោយសារភ្លៀងហូរច្រោះ ។ ពេលនោះ អ្នកឃើញមានគ្រឿងបរិក្ខារផ្សេងៗ សម្រាប់ធ្វើការនោះដែរ ។ ចូរអ្នកអធិប្បាយអំពីកិច្ចការទាំងនោះ ។

## ក. គោលសេចក្តី

១) សេចក្តីផ្តើម:

- ពេល,
- កន្លែងដែលគេកំពុងធ្វើការ;

២) អង្គសេចក្តី:

- កិច្ចការរបស់មនុស្សម្នាក់ៗ ក្នុងវេលានោះ,
- របៀបធ្វើការនៃជនទាំងនោះ;

៣) សេចក្តីបញ្ចប់:

- ប្រយោជន៍ខាងការគមនាគមន៍ ដោយសារការធ្វើនៃពួកកម្មករ ។

## ខ. សេចក្តីអធិប្បាយ

កាលពីថ្ងៃអាទិត្យមុន, ខ្ញុំបានជិះទោចក្រយានទៅកំសាន្ត

ទឹកខ្មៅ ៗ ប្រមាណម៉ោង៩ព្រឹក ខ្ញុំបានទៅដល់ភូមិចាក់អង្រែ

ត្រង់ទីនោះ ខ្ញុំក្រឡេកពីចម្ងាយ ឃើញមនុស្សម៉ឺរដេរដាស នៅខាងមុខ ហាក់ដូចជាមានកើតរឿងហេតុអ្វីមួយ ៗ លុះខ្ញុំដើ កាន់ទៅជិត ទើបបានដឹងថា ពួកកម្មករកំពុងធ្វើថ្នល់ ៗ មនុស្ស ទាំងនេះ ស្លៀកពាក់ខ្មៅទាំងស្រីទាំងប្រុស ៗ

ស្រី ៗ កណ្ដៀតបង្គីដាក់ថ្មពេញ ៗ ដញ្ជូនយកទៅចាក ក្រាលកណ្ដាលថ្នល់ ៗ ខ្លះដញ្ជូនគ្រួសដែលរែងយ៉ាងស្អាតយក ទៅចាក់លើថ្មដែលគិនរួចហើយ ៗ ស្រ្ដីមួយហ្វូងទៀតកំពុងយារ បបកាប់, បបត្រសេះគាស់កកាយ, ខ្លះបាំងថ្មបាស់ឲ្យរបើកឡើង ខ្លះទៀតកាន់អំបោស បោសគ្រាំសហុយធូលីយ៉ាងទ្រលោម ៗ ប្រុស ៗ មួយក្រុមនោះ កំពុងបាចទឹក, រែកទឹកមកចាក់លើថ្ម ដែលក្រាល ដើម្បីផ្សើមដីឲ្យជ្រាយសម្រាប់ឲ្យផុងលិចថ្មនៅពេល ណាដែលរូឡូគិនមកដល់ ៗ គឺនៅក្បែរកន្លែងនេះឯង ដែល មានរូឡូគិនថ្នល់កំពុងបរទៅបរមកគ្មានឈប់ឈរ ដើម្បីគិនថ្មឲ្យ លិចជាប់ទៅក្នុងដីព្រមទាំងឲ្យរាបស្មើផង ៗ នៅខាងស្ដាំដៃ,

មានម៉ាស៊ីនកំទេចថ្មមួយបញ្ឈរជ្រឹងនៅកណ្ដាលវាល សម្រាប់កំទេចថ្មណាធំៗឲ្យល្អិតម៉ដ្ឋទុកប្រើបាចសាចជាមួយដ័រកៅស៊ូ ៗ អ្នកបើកបរគ្រឿងយន្តទាំងនេះ សុទ្ធតែប៉ិនប្រសប់ ហើយធ្វើការរហ័សរហួនទាំងអស់ ព្រមទាំងបានស្អាតល្អហ្មត់ចត់ផង ៗ

ខាងណោះ កម្មករមួយផ្នែកទៀត, នៅឃ្លាតពីទីនេះបន្តិចត្រង់ផ្លូវដែលគេកិនរាបស្អាតរួចមកហើយ, កំពុងចាក់ដ័រកៅស៊ូ ៗ កុងទីជាមួយនេះ មានកូនរទេះតូចមួយ កំពុងបញ្ចេញសូររំពងដោយគ្រឿងចក្រ ដោយបន្តបំពង់កៅស៊ូមួយយ៉ាងវែងផ្ទុំខ្យល់ព្ឋសូរផែត! ផែត! ដើម្បីឲ្យជ្រះល្អងដីពីថ្ម ទុកបំរុងឲ្យខាំជាប់នឹងដ័រកៅស៊ូ ៗ មានប្រុសៗបួនប្រាំនាក់កំពុងចាប់ដម្រង់ចុងបំពង់ខ្យល់នេះ ទៅដាក់ត្រង់នេះម្ដង ត្រង់នោះម្ដងទាល់តែបានស្អាតគ្រប់កន្លែង ៗ ខាងណោះ រថកង់ពីរមួយគ្រឿងទៀតបាញ់ដ័រកៅស៊ូ ៗ នៅខាងចុងបំពង់ មានកម្មករម្នាក់ចាប់តម្រង់បាញ់ដ័រកៅស៊ូដែលនៅក្ដៅទៅលើផ្លូវមាគ៌ាហុយផ្សែងទ្រុប ៗ ស្រីៗខំប្រឹងជញ្ជូនកូនថ្មល្អិតៗ យកមកបាចសាចលើដ័រកៅស៊ូនោះ ដើម្បីឲ្យ

ខាំស្អិតជាប់គ្នានឹងថ្ម ។ ឯរុឡូមួយគ្រឿងទៀត មឺម្នាបើកបរចុះឡើងកិនកួចថ្មល្អិតៗ ទាំងនេះឲ្យរាបស្មើផង សម្រេចទៅជាវិថីមួយយ៉ាងល្អអស្ចារ្យ ។

លុះពិនិត្យមើលសព្វគ្រប់ហើយ ខ្ញុំក៏ធ្វើដំណើរបន្តទៅទៀតដោយនឹកតែក្នុងចិត្តថា :

“ ដោយសារកម្មករទាំងនេះឯង ទើបបានជាគមនាគមន៍ផ្សេងៗ ក្នុងប្រទេស មានសភាពស្អាតល្អ ដែលជាកម្លាំងជនជានរបស់រដ្ឋ ” ។

**កំរងតែងទី ៨**

ប្រធាន.- រាត្រីមួយ គ្រួសារអ្នកបានមកជួបជុំគ្នា ។ ចូរអ្នកអធិប្បាយអំពីមុខការ, កាយវិការរបស់មនុស្សទាំងអស់ក្នុងពេលនោះ ។

## ក. គោលសេចក្ដី

១ ) សេចក្ដីផ្ដើម :

- ពេល,
- កន្លែង,

២ ) អង្គសេចក្ដី :

- កិច្ចការរបស់មនុស្សម្នាក់ៗ ក្នុងវេលានោះ,
- កាយវិការរបស់ជនទាំងនោះ,
- កិច្ចការផ្ទាល់របស់អ្នក,

៣ ) សេចក្ដីបញ្ចប់ :

- ការជួបជុំគ្រួសារនេះ ហុចសេចក្ដីរីករាយ យ៉ាងក្រៃលែងដល់សមាជិកគ្រួសារម្នាក់ៗ ។

## ១. សេចក្ដីអធិប្បាយ

នាពេលយប់មួយ គ្រួសារខ្ញុំបានមកជួបជុំគ្នា អង្គុយនៅក្នុងបន្ទប់ធំចំកណ្ដាលផ្ទះ ។ បន្ទប់នេះ ប្រកបដោយអាកាសល្អ ស៊ឹងមានរាំយោបក់មកសេៀកៗ តាមបង្អួច ។ ពន្លឺចង្កៀងប្រេងកាតមួយ

ដ៏ធំបានបំភ្លឺយ៉ាងភ្លឺខែង ដល់ជនប្រាំពីរនាក់ដែលអង្គុយនៅជុំគ្នាទីនោះ ។

បិតាខ្ញុំទម្រេតខ្លួនសម្រាកនៅលើក្ដារងឿ ពីព្រោះគាត់នឿយហត់ក្នុងការធ្វើស្រែពីពេលថ្ងៃ ។ មាតាខ្ញុំអង្គុយត្បែរសសរកណ្ដាល ជិតចង្កៀង ដេរនឹងប៉ះសំលៀកបំពាក់ណាចាស់ៗ ។ ឯបងស្រីខ្ញុំអង្គុយក្រងអង្រឹងត្បែរអ្នកម្ដាយខ្ញុំដែរ តែគាត់មិនសូវបានធ្វើប៉ុន្មានទេ ព្រោះអាល័យតែស្ទុះក្រោកចុះក្រោកឡើងយកនេះបន្តិច យកនោះបន្តិច តាមបង្គាប់អ្នកម្ដាយរបស់ខ្ញុំ ។ ប្អូនប្រុសខ្ញុំម្នាក់ អាយុទើបបានប្រាំមួយឆ្នាំនឹងប្អូនស្រីខ្ញុំម្នាក់ទៀត អាយុប្រាំបួនឆ្នាំ វ៉ានៅទទូចទទៃត្បែរជីតារបស់ខ្ញុំ ដើម្បីឲ្យគាត់និទានរឿងព្រេងឲ្យវ៉ាស្ដាប់ ។ ពេលដែលជួបជុំគ្នាយ៉ាងនេះ ជីតាខ្ញុំច្រើននិទានរឿងប្លែកៗ នាំឲ្យសមាជិកគ្រួសារទាំងអស់គ្នា ប្រុងស្ដាប់ដោយយកចិត្តទុកដាក់ ។ មានពេលម្ដងៗដែរ ដែលអ្នកទាំងអស់គ្នាផ្ទុះសំណើចដោយសារគាត់ ។ ចំណែកខ្ញុំ ក៏នៅអង្គុយជិតចង្កៀងនោះដែរ ដើម្បីធ្វើកិច្ចការដែលលោកគ្រូដាក់ឲ្យ

ធ្វើ ។ លុះខ្ញុំបង្ហើយកិច្ចការទាំងនោះរួចហើយ ខ្ញុំទាញយកសៀវភៅមេទន្ទេញមកស្វាធ្យាយ ដើម្បីទុកសូត្រក្នុងពេលទៅរៀនថ្ងៃស្អែក ។ តែខ្ញុំទន្ទេញតិចៗ ដើម្បីទុកឱកាសដ៏រីករាយនោះដល់គ្រួសារខ្ញុំស្ដាប់ជីតានិទានរឿង ។ ដល់ខ្ញុំទន្ទេញចាំសព្វគ្រប់ហើយ ក៏ប្រមូលសៀវភៅទាំងប្រដាប់ប្រដារបស់ខ្ញុំទុកដាក់យ៉ាងស្រួលបួល រួចចូលមកស្ដាប់លោកតានិទានរឿង ។

គ្មានអ្វីសប្បាយរីករាយ ជាជាងពេលដែលបានជួបជុំគ្រួសារនេះទេ ។ ការជួបជុំគ្នានេះ ធ្វើឲ្យសមាជិកគ្រួសារម្នាក់ៗ ចេះស្រឡាញ់គ្នា រាប់រកគ្នាជាថ្មីតាមគន្លងភាតរភាព ។

## ពិពណ៌នា

សេចក្ដីណែនាំ .- ពិពណ៌នា គឺការថ្លែងរៀបរាប់យ៉ាងហូរហែអំពីទស្សនីយភាព, ទេសភាពណាមួយដែលយើងបានឃើញដោយជាក់ច្បាស់ ។ ដើម្បីសរសេរឲ្យបានល្អ, យើងត្រូវរៀបរាប់ឲ្យពិស្ដារ, ឲ្យច្បាស់លាស់ ហើយឲ្យជាក់ស្ដែងយ៉ាងល្អមើលដល់អ្នកអាន ហាក់ដូចជាអ្នកនោះ បានទៅឃើញទីកន្លែងនោះៗ ជាមួយយើងដែរ ។ ជាពិសេស, គប្បីសរសេរឲ្យបានហាក់ដូចជាមានរូបភាព នៅលើសេចក្ដីរបស់យើង ដែលអ្នកអាន អានទៅ ឃើញហាក់ដូចជាមានរូបរស់រវើកនៅលើផ្ទៃក្រដាសនោះ ។

គោលសំខាន់ ដែលយើងអាចសរសេរឲ្យបានល្អ គឺយើងត្រូវនិយាយពីៈ

១) អ្វីដែលយើងឃើញ,

២) អ្វីដែលយើងឮ,

៣) អ្វីដែលយើងធុំក្លិន,

៤) អ្វីដែលយើងចាប់អារម្មណ៍ជាប់ចិត្តជាងគេ ។

## ក. ពិពណ៌នាពីធម្មជាតិ

( Description de la nature )

សេចក្តីណែនាំ .- ការធ្វើពិពណ៌នាអំពីធម្មជាតិ ជាការងាយជាងគេបំផុតក្នុងរបៀបតែងសេចក្តី ព្រោះប្រធានទីមួយៗដែលគេដាក់ឲ្យ អាចបើកទ្វារគំនិត ឲ្យអ្នកសរសេរបានវែងឆ្ងាយទូលំទូលាយណាស់ ។ ប៉ុន្តែត្រូវអ្នកប្រតិបត្តិតាមគោលខ្លះៗដូចតទៅ ៖

១) ត្រូវអធិប្បាយ ឲ្យច្បាស់លាស់ អំពីទិដ្ឋភាពអ្វីមួយដែលប្រធានបានតម្រូវឲ្យតែង ។

២) ត្រូវសរសេរឲ្យឃើញ បម្រស់ទិដ្ឋភាពនោះ ហាក់ដូចជារស់រវើកបង្ហាញអ្នកអានឲ្យឃើញជាក់ច្បាស់មែនទែន ។

៣) ត្រូវប្រយ័ត្នពាក្យពេចន៍ ឃ្លា ល្បះ និងត្រូវសរសេរឲ្យត្រូវតាមន័យរបស់ប្រធានដែលគេដាក់ឲ្យ ។

៤) គោលសំខាន់បំផុត គឺយើងត្រូវចេះនិយាយពីអ្វីដែលយើងមើលឃើញ, អ្វីដែលយើងឮ, អ្វីដែលយើងចាប់ចិត្ត និងយោបល់ដែលយើងនឹកឃើញចំពោះរូបសម្រស់នៃទិដ្ឋភាពនោះៗ

**គំរូតែងទី៩**

ប្រធាន.- រាត្រីមួយ មានព្រះចន្ទរះពេញវង់យ៉ាងភ្លឺត្រចះៗ អ្នកបានដើរទៅកំសាន្តលេងនៅមាត់ទន្លេ ។ ចូរអ្នករៀបរាប់អំពីទស្សនីយភាពដែលអ្នកបានឃើញក្នុងវេលានោះ ។

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម:

- ទីកន្លែង,
- ពេលវេលា;

២) អង្គសេចក្ដី:

- រៀបរាប់ពីសភាព, បរិយាកាសទាំងពីអ្វីដែលយើងបានឃើញបានឮក្នុងវេលានោះ ,

៣) សេចក្ដីបញ្ចប់:

- ការចាប់អារម្មណ៍លើទិដ្ឋភាពនារាត្រីនោះ ។

## ខ. សេចក្ដីអធិប្បាយ

ព្រះសុរិយាអស្ដង្គតរលត់បាត់ស្ងាត់អស់កាលជាយូរបន្តិចទៅ

ហើយ រាត្រីកាលក៏បានលាតសន្ធឹងស្បៃខ្មៅមកគ្របដណ្ដប់លើផែនពសុធា ។

វេលានោះ ខ្ញុំបានដើរទៅលំហើយយកខ្យល់អាកាសល្អនៅមាត់ទន្លេមុខព្រះបរមរាជវាំង ដែលជនានុជនក្នុងក្រុងបានចាត់ទុកជាទីមនោរម្យមួយយ៉ាងប្រសើរត្រកាល ។

សន្ទើមសន្ទ្រឹមពេលនោះ ទម្ងាក់ផងលំអងដ៏ល្អិតម៉ត្ត ផ្សែមអស់ទាំងធម្មជាតិនានាមានបុប្ផជាតិ ទឹងតិណជាតិដែលដុះជាលំអក្នុងទីនោះជាដើម ។ ទិដ្ឋភាពក៏ប្រែក្លាយពីភាពស្ងួតស្រពោនទៅជាស្រស់ញញឹមប្រិមប្រិយ គួរជាទីរីករាយយ៉ាងក្រៃលែង ។ មួយស្របក់ប៉ុណ្ណោះ ដើងមេឃនាទិសបូព៌ាឡើងពណ៌ថ្លាត្រចះ ព្រោះព្រះនិសាករ បានតើនចាកព្រះទែនសយនា អណ្ដែតលេចឡើងតាមចន្លោះមែកព្រឹក្សខ្ពស់បន្តិចម្ដងៗ លុះត្រាតែផុតស្រឡះពីភាពស្រអាប់ទាំងនោះ ។ ក្នុងពេលជាមួយគ្នានេះ ទឹកទន្លេក៏ប្រែពណ៌ទៅជាសរលោងហាំងស្មើព្រាតៗ រត់រមេញប្រដេញគ្នាគ្មានឈប់ឈរ ។ ផ្ទៃមេឃឡើងពណ៌ខៀវស្រឡះ លាតសន្ធឹង

យ៉ាងធំធេង យូរៗ ទើបឃើញដុំពពកខ្មៅតូចមួយ អណ្ដែតទៅបាំងរស្មីចន្ទ្រា នាំឲ្យផែនពសុធាស្រអាប់ពណ៌មួយភ្លែតទៅដែរ ។ បំណែកម្ខាងតារាវិញ មិនឃើញលេចរូបមកបង្អួតរាងដូចជារាត្រីខាងរនោចនោះឡើយ ដោយហេតុបាញ់បារមីនៃព្រះនិសាករ ។ តែគេឃើញមានបីបួនដែរ ដែលខំត្រដរមកប្រឡងនឹងចេស្ដានៃស្ដេចរាត្រី ។

ពន្លឺដ៏ត្រចះត្រចង់នេះ បានដាស់ពពួកសត្វរាត្រីចរទាំងឡាយ ឲ្យទៅស្វែងរកអាហារចិញ្ចឹមជីវិត ។ ខាងណោះចង្រិតដែកមួយ កំពុងយំព្រេកៗ ក្រោមគុម្ពស្មៅ ហាក់ចេះហៅរកគូវា ។ មើលន៏! អ្នកកំសាន្តទាំងឡាយនាំគ្នាឈរលំហែលំហើយខ្លួនតាមពួកតាមក្រុម, ខ្លះអង្គុយលើផ្ទៃស្មៅក្នុងសួន ហើយខ្លះទៀតអង្គុយលើកៅអីស៊ីម៉ងត៍វែង ។ នេត្រានៃជនម្នាក់ៗតែងបាញ់ឆ្ពោះទៅរកទស្សនីយភាពដ៏ស្រស់ត្រកាលនៃទន្លេចតុមុខ ។ នោះ, នៅកណ្ដាលមហានទីកូនទូកតូចៗរបស់ពួកនេសាទ កំពុងអណ្ដែតខ្លួនក្រោមរស្មីនៃចន្ទ្រា ។ ខាងណោះ កូនទូកស្រយួន

អ្នកលក់បបរសណ្តែក បបរត្រី កំពុងពាយនាយឡើយៗដើម្បីហៅអ្នកកំសាន្តឲ្យបរិភោគសម្រន់លេង ៗ ក្រឡេកទៅឆ្ងាយពីផ្នូរបន្តិច ឃើញពពួកវារីរុក្ខជាតិកំពុងឌុនដើបៗ ព្រោះត្រូវកំឡាំងវាយោបក់ពីឧត្តរ ហាក់ប្រឹងត្រដរធ្វើនូវកិច្ចចំពោះព្រះចន្ទ ៗ ឱហ្ន៎! ទិដ្ឋភាពនេះ សប្បាយអ្វីម្ល៉េះទេ!

ដួងវិញ្ញាណនឹងមនោគតិរបស់ខ្ញុំ ថតផ្ចិតជាប់នូវទស្សនីយ-ភាពទាំងនេះ ព្រោះថា គ្មានអ្វីធ្វើឲ្យសប្បាយរីករាយជាជាងការដើរកំសាន្តតាមមាត់ទន្លេ នារាត្រីដែលមានព្រះចន្ទរះពេញវង់ដូចនេះឡើយ ៗ

## គំរូតែងទី ១០

ប្រធាន .– ចូរអធិប្បាយអំពីការសំអាត ដែលអ្នកត្រូវធ្វើជារៀងរាល់ថ្ងៃ ៗ

(វិញ្ញាបនប័ត្រ ឆ្នាំ ១៩៥៨)

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម :

- ពេល,
- ទីកន្លែង ;

២) អង្គសេចក្ដី :

- របស់ដែលគេត្រូវសំអាតជាដំបូង ( ខ្លួនប្រាណនិងសំលៀកបំពាក់ )
- ចំណីអាហារ ទឹក . . .
- ប្រដាប់ប្រើប្រាស់ ,
- ដំណេក, ផ្ទះសំបែង ,
- ផលប្រយោជន៍នៃការសំអាត ;

៣) សេចក្ដីបញ្ចប់ :

- តើយើងយល់ដូចម្ដេចខ្លះចំពោះការសំអាតនេះ ?

## ខ. សេចក្ដីអធិប្បាយ

មនុស្សនីមួយៗ ដែលនឹងរស់នៅដោយសុខសប្បាយ

ហើយមានសុខភាពគ្រប់គ្រាន់ ព្រោះបេះសំអាតខ្លួនប្រាណ ។
ដូច្នេះខ្ញុំត្រូវសំអាតសរីរាង្គកាយឲ្យត្រូវតាមក្បួនអនាម័យ ។

ជាបឋម ខ្ញុំត្រូវសំអាតសព្វខ្លួនប្រាណ ។ រាល់ថ្ងៃ ខ្ញុំតែង
ងូតទឹកដុសលាងខ្លួននឹងសាប៊ូ ដើម្បីឲ្យស្បែកបានស្អាត ហើយ
ញើសក៏អាចចេញមកក្រៅបានដោយស្រួល ។ កាលបើញើស
ចេញបានស្រួលហើយ ធាតុដែលទ្រទ្រង់រូបរាងខ្ញុំ មុខជាបានសុខ
ស្រួលមិនខាន ។ ក្របកដៃក្របកជើង ខ្ញុំត្រូវកាត់តម្រឹមឲ្យខ្លី
ហើយឆ្កើសក្អែលឲ្យអស់ ព្រោះក្អែលក្រខ្វក់នេះនឹងបណ្ដាលឲ្យ
កើតរោគក្រៅស្បែកផ្សេងៗ បាន នៅពេលដែលខ្ញុំយកដៃនោះ
ទៅអេះឬប៉ះពាល់ដល់ខ្លួនប្រាណ ។ ឯសក់ក្បាលក៏ត្រូវកក់នឹង
សាប៊ូជាញឹកញយដែរ ដើម្បីជៀសវាងកុំឲ្យកើតមានចៃឬកើត
អង្គែ ដែលជាមេរោគនាំឲ្យវិនាសដល់សុខភាព ។ ធ្មេញទាំង
ឡាយលើក្រោម ខ្ញុំត្រូវដុសលាងដោយច្រាស់ផ្សែមនឹងថ្នាំឬ
សាប៊ូ ដើម្បីឲ្យបានស្អាតនឹងកុំឲ្យធុំក្លិនអសោច ដែលជាហេតុ
នាំឲ្យឆាប់ខូចធ្មេញ ។

បន្ទាប់ពីការសំអាតខ្លួនមក ខ្ញុំត្រូវសំអាតសំលៀកបំពាក់ដែលមានក្អែលពុំស្អាត ព្រោះក្អែលអាក្រក់នេះ វាជាសំបុកមេរោគមួយយ៉ាងធំ ហើយនាំឲ្យអ្នកដទៃខ្ពើមរអើមផង ។ បំណែកប្រដាប់ប្រដាសម្រាប់ប្រើប្រាស់ផ្សេងៗទៀត ក៏ខ្ញុំត្រូវថែជួនឲ្យបានស្អាតបាតដែរ ។ រីឯម្ហូបចំណីវិញ ខ្ញុំត្រូវប្រយ័ត្នជាទីបំផុត ព្រោះជួនណាអាហារម្ហូបទឹកដែលយើងលេបចូលទៅក្នុងពោះនោះ បណ្ដាលឲ្យមានជម្ងឺក៏សឹងមាន ត្បិតនៅក្នុងម្ហូបទឹកមិនតុះ ច្រើនតែមានសត្វមេរោគល្អិតៗ ដែលយើងមិនអាចមើលឃើញដោយភ្នែកទទេបាន ។ ផ្ទះសំបែងនិងទីដំណេកសោតខ្ញុំត្រូវតែបោសសំអាតដោយមធ្យ័ត ព្រោះកាលបើវាក្រខ្វក់ វានឹងក្លាយទៅជាទីប្រជុំនៃសត្វមេរោគគ្រប់បែបគ្រប់យ៉ាង ។ មុននឹងចូលដំណេក ខ្ញុំតែងបោសប្រាស់ឲ្យអស់ធង់ធូលី កុំឲ្យមានសល់ជាប់នៅនឹងមុងពូកឬខ្នើយបាន ។

ការសំអាតនេះ ហុចផលប្រយោជន៍ដល់អ្នកប្រព្រឹត្តច្រើនបែបច្រើនយ៉ាងណាស់ ។ ជាបឋម គឺនាំឲ្យល្អមើលដល់ខ្លួន

ឯងទីងអ្នកដទៃ ដែលបានជួបប្រទះឃើញខ្លួនយើង ឬផ្ទះសំបែង
របស់យើង ។ ក្រៅពីនេះ នាំឲ្យរូបកាយយើងមានសុខភាពដ៏
សម្បូណ៌ ប្រកបដោយជីវភាពរស់នៅយ៉ាងសុខក្រេមក្សាន្ត
មានកម្លាំងពលំមិនបេះទ្រុឌទ្រោម ។ មួយទៀត ការសំអាត
មិនមែនជាលំបាក, ខាតពេលវេលា ឬថ្លៃណាស់ណាទេ នរណា
មួយក៏អាចធ្វើបានយ៉ាងស្រួលដូចៗគ្នា ។ ដូច្នេះ គួរតែយើង
សំអាតខ្លួនប្រាណឲ្យត្រឹមត្រូវតាមក្បួនអនាម័យ ដើម្បីឲ្យជីវិត
យើងរស់នៅដោយសេចក្ដីសុខសាន្ត ។

## ១. ពិពណ៌នាពីធាតុភូត

(Description de phénomènes)

សេចក្ដីណែនាំ. - ការធ្វើពិពណ៌នាពីធាតុភូត គឺការរៀបរាប់ពី អ្វីមួយដែលឧប្បត្តិឡើងយ៉ាងស្រពន់ ទាញចិត្តអ្នកផងឲ្យភ្ញាក់ ផ្អើលដោយសារ ដូចជាភ្លៀង, អគ្គិភ័យ, ខ្យល់ព្យុះ, ទឹក ជំនន់, ពេលថ្ងៃរះ ពេលព្រះអាទិត្យអស្ដង្គតជាដើម ។

ដើម្បីសរសេរឲ្យបានល្អពីធាតុភូត, ដំបូង គេត្រូវចាប់រៀប រាប់អំពីបុព្វហេតុដែលកើតឡើងមុនកំណើតធាតុភូតនោះរួចទើប អធិប្បាយអំពីដំណាក់ៗផ្សេងៗនៃធាតុភូត រហូតដល់ពេលដែល ធាតុភូតរលត់បាត់ទៅវិញ ដោយរើសយកហេតុណាដែលថ្ងៃ អាចធ្វើឲ្យកម្រើកដល់ដួងចិត្តដួងវិញ្ញាណអ្នកអានមកបរិយាយ

ទីបំផុត, គេបញ្ចប់ការតែង ដោយបញ្ជាក់អំពីការចម្រើន ឬការអន្តរាយ ដែលកើតឡើង ឬបណ្ដាលឡើងព្រោះធាតុភូ នោះ ឬក៏ដោយបញ្ចេញការចាប់អារម្មណ៍ នឹងយោបល់បេ ខ្លួនចំពោះធាតុភូតនោះ ។

**កំរូតែង ទី ១១**

ប្រធាន.— អ្នកបានជួបប្រទះខ្យល់ព្យុះមួយ ចូរអ្នកអធិប្បាយអំពីខ្យល់ព្យុះនេះ តាមលំនាំខាងក្រោម ៖

- មុនខ្យល់ព្យុះ ,
- កំពុងខ្យល់ព្យុះ ,
- ក្រោយខ្យល់ព្យុះ ,
- យោបល់របស់អ្នក ។

(វិញ្ញាបនប័ត្រ ឆ្នាំ ១៩៥០)

## ក. គោលសេចក្តី

១) សេចក្តីផ្តើម :

- ទីកន្លែង ,
- ពេលវេលា;

២) អង្គសេចក្តី :

- រៀបរាប់ពីសភាព, បរិយាកាស និងពីអ្វីៗ ដែលយើងបានឃើញបានឮ ក្នុងពេលមុន-កំពុង-ក្រោយខ្យល់ព្យុះនោះ ;

៣) សេចក្ដីបញ្ចប់ :

— យោបល់របស់អ្នកលើខ្យល់ព្យុះនោះ ។

## ១. សេចក្ដីអធិប្បាយ

កំដៅព្រះសុរិយាខែជេស្ឋ កំពុងផ្សាយកាំរស្មីយ៉ាងយោរយៅមកលើផែនពសុធា ធម្មជាតិនានាក្នុងភូមិខ្ញុំ ធ្លាក់ក្នុងសភាពក្រៀមក្រំយ៉ាងស្ងប់ស្ងាត់ ។

ថ្ងៃនោះ ព្រះអាទិត្យជ្រេបន្តិចទៅហើយ កាំរស្មីក៏បន្ថយអំណាចកំដៅបន្តិចទៅដែរ ។ ផ្ទៃនភាល័យទាំងមូល ដែលស្រឡះគ្មានខ្មៅអម្បាញ់មិញនោះ ស្រាប់តែប្រែសភាពយ៉ាងរហ័ស បង្កើតទៅជាមានដុំពពកខ្មៅៗមួយរំពេច ។ ព្រះពាយបក់មកពីទិសនិរតីតែខ្លាំងឡើងៗ រុញច្រានទូវដុំពពកខ្មៅដែលគេហៅថា "ពពកទឹក" ឲ្យរសាត់មកគ្របដិតលើផ្ទៃភូមិខ្ញុំទាំងមូល មើលទៅឃើញហាក់ដូចជាមហាមេឃស្រុតធ្លាក់មកជិតផែនប្រថពី ។

ប្រហែលបីបួននាទីប៉ុណ្ណោះ នាដើមមេឃ សភាពខ្មៅស្រុប

ផ្សព្វផ្សាយគ្រប់ទិសទីយ៉ាងងងឹតសូន្យសុង ៗ សូរស័ព្ទគុក ៗ លេចឮសន្ធាប់មកពីទិសនិរតី បីដូចជាសូរមហន្តរាយអ្វីមួយយ៉ាងយោរយៅ មកគ្របសន្ធាប់លើភូមិកំសត់នេះ ដោយឥតប្រណី ៗ គឺជាខ្យល់ព្យុះមួយយ៉ាងកំណាច ៗ ស្លឹកក្រខ្លាលតាវល្លិ៍រណ្ដំបោកបែនលើគ្នាលាន់ឮសូរក៉ាវៗ ខ្លះបាក់មែកបាក់ធាង ខ្លះទៀតរលើងគល់រលំធាង ៗ ស្លឹកឈើណាដែលក្រៀមៗ ឬទុំស្ងួត ត្រូវរបើកបាកទងប៉ុងខ្ចាត់ខ្ចាយទៅគ្រប់ទិសទី ៗ ឯផង់ធូលីលើពសុធាក៏ហុយយ៉ាងទ្រលំទ្រលោម ស្ទើរតែរកមើលអ្វីមិនឃើញ ៗ ទ្វារបង្អួចគេហដ្ឋានណាដែលធំៗ ត្រូវប៉ើងបោកទង្គិចលើមេព្រែត ផ្ទួនផ្ទាំង ; លំនៅណាដែលតូចៗ ប្រក់ស្លឹកត្រូវរបើកដំបូល ខ្ចាតជញ្ជាំងធ្លាក់មកដី ៗ ជនកំសត់ដែលជាម្ចាស់ផ្ទះទាំងនោះ រត់ប្រសេចប្រសាចប្រមែប្រមូលរបស់របរ ដើម្បីគេចអំពីអន្តរាយ ៗ ខ្លះស្រែកប្រគួករហៅរកកូនចៅ ៗ ខ្លះទៀតស្រែកបង្អើលមេខ្យល់កំណាចនេះឲ្យបក់ផាត់ចៀសផុតអំពីលំនៅខ្លួន ៗ សត្វចិញ្ចឹមដូចជាមាន់ទា ជ្រូក ជាដើម ផ្អើលរត់ឆោឡោ ៗ រីឯហ្វូងគោ-ក្របី

វិញ ក៏បោលប្រសេចប្រសាចរត់រកលំនៅម្ចាស់ ៗ សូរសម្រែកក្មេងតូចយំរកម្ដាយ សូរម្ដាយស្រែកហៅកូន និងសូរសត្វធាតុស្រែករវើករវ៉ាកយ៉ាងទ្រហឹងអឹងកង ៗ

អស់រយៈវេលាប្រមាណជាងកន្លះម៉ោង ទើបបានព្យុះកំណាចបន្ថយនូវឫទ្ធិបន្តិចម្ដងៗ ៗ ឯភូមិកំសត់ក៏ប្រែសភាពស្រស់បស់ឡើងៗ ជាលំដាប់ដែរ ៗ គេឃើញជនទាំងឡាយណា ដែលមានផ្ទះត្រូវមហាវាយោបក់បំបើងដំបូលឬជញ្ជាំង ក៏ខំដើររើសប្រមូលយកមកជួសជុលវិញ ៗ ពួកស្រីៗ ក៏ចូលទៅដណ្ដាំស្ល សម្រាប់អាហារពេលល្ងាច ៗ ខ្លះដើរបោសសម្រាម និងកំទេចស្លឹកឈើ ដើម្បីសំអាតទីធ្លាមុខផ្ទះ ៗ ចំណែកពពួកកូនក្មេងតូចៗ នាំគ្នារត់ទៅរករើសផ្លែឈើ ប្រញាយ ៗ

ឧបទ្ទវហេតុដ៏ឃោរឃៅនេះ ធ្វើឲ្យអ្នកស្រុកគ្រប់ភូមិគ្រប់ដំបន់ ខ្លាចក្រែងរអាចិត្តគ្រប់ៗ គ្នា ព្រោះវាបំផ្លាញឲ្យហិនហោចទាំងសព្វគ្រប់ តាំងពីដំណាំដាំដុះនិងទីលំនៅជាដើមឡើងទៅ ៗ

កំរូតែងទី ១២

ប្រធាន.– ភ្លៀងមួយមេកំពុងធ្លាក់មកយ៉ាងខ្លាំង ៗ អ្នកឈរនៅមាត់បង្អួចរបស់អ្នក ៗ ចូរអ្នករៀបរាប់ពីអ្វីដែលអ្នកបានឃើញ, បានឮក្នុងវេលានោះ ៗ

(វិញ្ញាបនប័ត្រ ឆ្នាំ១៩៥២)

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម :

– កន្លែង,

– ពេលដែលកំពុងភ្លៀង ;

២) អង្គសេចក្ដី :

– ភាពនានាដែលយើងបានឃើញ ទឹងសូរសព្ទផ្សេងៗ ដែលយើងបានឮក្នុងពេលដែលកំពុងភ្លៀងនោះ ៗ

៣) សេចក្ដីបញ្ចប់ :

– តើមានប្រយោជន៍ដល់យើងទេ ?

## ១. សេចក្ដីអធិប្បាយ

វេលាមួយ ជាពេលថ្ងៃរសៀលទាបបន្តិចហើយ មានភ្លៀងមួយមេធំបង្អុរមកយ៉ាងខ្លាំង ៗ ទីក្រុងទាំងមូលស្ថិតនៅក្នុងសភាពប្លែកខុសពីប្រក្រតី ។

គ្រានោះ ខ្ញុំឈរនៅក្បែរមាត់បង្អួច ហើយក្រឡេកមើលទៅទិដ្ឋភាពសព្វទិសទី ដែលកំពុងតែរងកម្លាំងទឹកភ្លៀងយ៉ាងខ្លាំងសំបើមអស្ចារ្យ ។ លើដំបូលគៀងផ្ទះខ្ញុំ ឫស្សូរព្រាវ ៗ ជួនតិចជួនខ្លាំង បីដូចជាមនុស្សរត់ប្រដេញគ្នានៅលើនោះ ។ បំណែកដើមស្វាយ, មៀន, ត្របែកនឹងទៀបដែលដុះក្នុងរបងភូមិខ្ញុំ មែកធ្លាក់ទោរទន់ បីដូចជាមានទម្ងន់ធ្ងន់ប្លែក ហើយស្ងប់ឈឹងឥតមានកំរើកមែកធាងឬស្លឹកបន្តិចឡើយ ។ ប៉ុន្តែផ្ទុយទៅវិញ រុក្ខជាតិណាដែលនៅមានកម្លាំង ក៏ត្រូវព្រះពិរុណទម្លាក់ខ្លួនមកលើឫស្សូររ៉ាវៗ ឥតស្រាកស្រាន្ត ។ ទឹកហូរពីទរធ្លាក់ខ្លោក ៗ ទៅក្នុងពាងពេញហូរហៀរ ។ ផែនពសុធាក៏ជោកជាំទៅដោយទឹក ដែលហូរកាត់ធ្លាក់ថ្លែងចុះពីទួលទៅរកទីទំនាប ។ នៅ

លើវិថីខាងមុខផ្ទះខ្ញុំ ដែលពីមុននេះកំពុងមានមនុស្សកុះករនោះ ឥឡូវក៏ប្រែជាស្ងាត់ស្ងៀមយូរៗ ទើបគេឃើញមានរថយន្ត បើកមកម្ដង ហើយបាចសាចទឹកឡើងសសំពោង បីដូចជារលក ក្នុងទន្លេនៅគ្រាដែលមានខ្យល់ព្យុះសង្ឃ្រា ។ រីឯតិណជាតិនឹង កូនរុក្ខជាតិតូចតាចដែលដុះតាមរបងផ្ទះខ្ញុំ បែរជាមានសភាព ស្រស់ញញឹម ឡើងពណ៌បៃតងខ្ចីបំព្រង គួរជាទីឆ្ងាញ់ពិសា ដល់សត្វពាហនៈទាំងឡាយ ។

ភ្លៀងអាចផ្ដល់ប្រយោជន៍ឲ្យមនុស្សច្រើនណាស់ ដូចជាជួយ ធ្វើឲ្យមានទឹកប្រើប្រាស់, ធ្វើឲ្យដំណាំដាំដុះលូតលាស់ល្អ ហើយ នឹងបំពេញទឹកក្នុងស្រែ សម្រាប់កសិករធ្វើស្រូវទៀតផង ។ ប៉ុន្តែ បើភ្លៀងធ្លាក់ច្រើនពេក បែរជានាំឲ្យរលួយដំណាំដាំដុះអ្នក ស្រុកទៅវិញ ។ មិនតែប៉ុណ្ណោះ វាធ្វើឲ្យខកខានដល់អ្នកដំណើរ ណាដែលមានធុរៈជាបន្ទាន់ថែមទៀត ។ ទុកជាដូច្នេះក៏ដោយ ភ្លៀងពិតជាការចាំបាច់មួយរបស់មនុស្សជាតិ ។

## សំបុត្រ

សេចក្ដីណែនាំ.– សំបុត្រ គឺការសន្ទនាគ្នាជាលាយល័ក្ខណ៍អក្សរ ជាមួយនឹងជនដែលនៅឆ្ងាយពីខ្លួន ។

សំបុត្រមានបីបែបគឺ៖

១) សំបុត្រដែលផ្ញើទៅមកចំពោះក្រុមគ្រួសារឬចំពោះមិត្តភក្ដិជាទីស្និទ្ធស្នាល ។ សំបុត្រនេះត្រូវសរសេរឲ្យងាយយល់ ហើយដោយផ្ចិតផ្ចង់ផង ។

២) សំបុត្រដែលគេសរសេរទៅកាន់ឯកជនឬទៅកាន់អ្នកជំនួញ ក្នុងផ្លូវពាណិជ្ជកម្ម ។ គេត្រូវសរសេរសំបុត្រចំពូកនេះឲ្យច្បាស់លាស់ហើយមានសេចក្ដីខ្លី ។

៣) ពាក្យ គឺជាសំបុត្រមួយបែប ដែលគេសរសេរទៅកាន់រាជការ ដើម្បីសុំកន្លែងធ្វើការ ឬសុំអនុគ្រោះអ្វីមួយ ។ សំបុត្រនេះត្រូវប្រើពាក្យពេចន៍ឲ្យសមគួរជាទីបំផុត នឹងឲ្យច្បាស់លាស់ហើយផ្ចិតផ្ចង់ទៀត ។

សំបុត្រទាំងឡាយតែងមានរបៀបដូចនេះ៖

ក) ដើមសំបុត្រ គឺត្រូវដាក់ទីកន្លែង; កាលបរិច្ឆេទ និង ឋានន្តរស័ក្តិអ្នកទទួលលិខិត ;

ខ) តួនៃសំបុត្រ ;

គ) សេចក្ដីបញ្ចប់និងហត្ថលេខា ។

សេចក្ដីពិសេស.- ការសរសេរសំបុត្រ គួរចាត់ទុកជាការមួយសំខាន់ យើងត្រូវតែសរសេរដោយផ្ចិតផ្ចង់ ព្រោះវាជាទីប្រជុំខាងអក្សរសាស្ត្រ ហើយមានទាំងគំរូបភាព, ពិពណ៌នា ការរៀបរាប់ផ្សេងៗ ជាច្រើនទៀត ។

# សំបុត្រគ្រួសារឬមិត្តភាព
## ( Lettres familiales ou amicales )

**កំរងទី ១៣**

ប្រធាន. — ចូរអ្នកសរសេរសំបុត្រទៅមិត្តអ្នកម្នាក់ ដើម្បីឲ្យមកកំសាន្តលេងនៅផ្ទះអ្នក ក្នុងពេលវិស្សមកាល ។

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម :

- ទីលំនៅ,
- កាលបរិច្ឆេទ ,

២) តួសំបុត្រ :

- សេចក្ដីនឹករលឹក ,
- បញ្ជាក់ពីការកំសាន្ត ,
- សេចក្ដីសុខទុក្ខនិងបែបនិងបទ ;

៣) សេចក្ដីបញ្ចប់ :

- ពរស័ព្ទសាធុការ

- ហត្ថលេខា ។

# ១. សេចក្ដីអធិប្បាយ

បាត់ដំបង, ថ្ងៃទី ១០ កក្កដា ១៩៥៧

បិយមិត្ត !

ខ្ញុំមានសេចក្ដីត្រេកអរជាទីបំផុត នឹងមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដើម្បីអញ្ជើញមិត្តមកកំសាន្តលេងនៅគេហដ្ឋានរបស់ខ្ញុំ ក្នុងឱកាសវិស្សមកាលនេះ ។ មិនត្រឹមតែខ្ញុំទេដែលទន្ទឹងចាំមើលផ្លូវមិត្ត សូម្បីតែមាតាបិតានឹងសាច់ញាតិរបស់ខ្ញុំ ក៏មានសេចក្ដីរីករាយជាមុន ដើម្បីនឹងចាំទទួលមិត្ត ព្រោះគាត់ដឹងថាមិត្តជាមនុស្សសុភាពរាបសាហើយត្រឹមត្រូវ ។ ដូច្នេះ សូមមិត្តកុំប្រកែកនូវសេចក្ដីអញ្ជើញរបស់ខ្ញុំឡើយ ។ ពិសេសទៅទៀត, ខ្ញុំបានព្រាងទុកជាស្រេច នូវកម្មវិធីរបស់យើង គឺដើរកំសាន្តតាមមាត់ព្រែក ដើម្បីសូបត្រី, ដើរលេងតាមវាលស្រែ, ទៅលេងបឹង, អុំទូកប្រណាំង ។ល។

មួយវិញទៀត បើមិត្តប្រុងនឹងធ្វើដំណើរមក សូមមិត្តឲ្យដំណឹងខ្ញុំជាមុនសិន ។ ខ្ញុំនឹងទៅរង់ចាំទទួលមិត្ត នៅស្ថានីយរាជអយស្ម័យយាន ។

ទីបំផុតនេះ ខ្ញុំសូមជំរាបសួរសុខ-ទុក្ខលោកពុកអ្នកម្ដាយនិងប្អូនៗរបស់មិត្ត ដោយសេចក្ដីគោរពនឹងនឹករលឹកជានិច្ច ។

សូមឲ្យវត្ថុស័ក្តិសិទ្ធិជួយថែរក្សាលោកពុកអ្នកម្ដាយនិងមិត្តព្រមទាំងគ្រួសាររបស់មិត្តអស់កាលជានិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ ។

បិយមិត្តរបស់ឯង

សុខ-សម្បត្តិ



ប្រធាន .- ចូរអ្នកសរសេរសំបុត្រផ្ញើទៅញាតិអ្នកម្នាក់ដែលនៅស្រុកឆ្ងាយ ប្រាប់ពីគោលបំណងរបស់អ្នក តើអ្នកប្រុងធ្វើអ្វីខ្លះ ប្រសិនបើអ្នកប្រឡងជាប់ក្នុងគ្រានេះ ។

(វិញ្ញាបនប័ត្រ ឆ្នាំ ១៩៥៣)

## ក. គោលសេចក្តី

១) សេចក្តីផ្តើម :

- ទីកន្លែង ,
- កាលបរិច្ឆេទ ;

២) តួសំបុត្រ :

- សេចក្តីនឹករលឹក ,
- បញ្ជាក់ពីគោលបំណងយើង ,
- សេចក្តីសុខទុក្ខបន្តិចបន្តួច ;

៣) សេចក្តីបញ្ចប់ :

- ពរសព្វសាធុការ ,
- ហត្ថលេខា ។

## ខ. សេចក្តីអធិប្បាយ

ភ្នំពេញ, ថ្ងៃទី ៦ មិថុនា ១៩៥៣

សូមជំរាបមកលោកគ្រូ

សូមជ្រាប ។

អស់កាលជាយូរណាស់មកហើយ ក្មួយពុំដែលបានផ្ញើសំបុត្រមកសួរសុខ-ទុក្ខលោកពូសោះ ព្រោះជាប់នឹងកិច្ចសិក្សាខ្លាំងពេក ប៉ុន្ដែក្មួយតែងមានចិត្តនឹករលឹកមកលោកពូ អ្នកមីងព្រមទាំងប្អូនៗ ជារឿយៗដែរ ។ ឱកាសនេះ ខ្ញុំបានពេលទំនេរបន្តិចផ្ទៀតសរសេរសំបុត្រនេះផ្ញើមកលោកពូ គ្រាន់បានជាដំណឹងខ្លះអំពីជីវភាពរបស់ក្មួយ ។

លោកពូ! ថ្ងៃប្រឡងយកវិញ្ញាបនប័ត្រ កាន់តែរំកិលចូលមកជិតហើយ លោកគ្រូកំពុងបង្ខំឲ្យសិស្សប្រឹងប្រែងរៀនយ៉ាងម៉ឺងម៉ាត់ សព្វវិជ្ជាដែលត្រូវប្រឡង ។ ហេតុនេះហើយបានជាការរវល់របស់ក្មួយរឹតតែខ្ជាន់ឡើងៗ ជារៀងរាល់វេលា ។ ប៉ុន្ដែរឿងប្រឡងនេះ ក្មួយពុំសូវជាព្រួយប៉ុន្មានទេ ដោយក្មួយសង្ឃឹមលើខ្លួនឯងថា មុខជាប្រឡងជាប់ជាពុំខាន ។ បើសិនជាបានជាប់មែន នោះខ្ញុំមុខជារឹតតែរវល់ខ្លាំងណាស់ទៅទៀត ព្រោះត្រូវប្រុងប្រៀបខ្លួននឹងប្រឡងប្រជែងចូលរៀនថ្នាក់ទី៦ទំនើប ក្នុងវិទ្យាល័យតទៅទៀត ។

លោកគ្រូ! បើគិតទៅតាមឋានៈគ្រួសារខ្ញុំ គួរណាស់តែខ្ញុំរៀនត្រឹមណោះ ចេញមករកសុំការងារអ្វីធ្វើ ដើម្បីយកបៀវត្សរ៍ចិញ្ចឹមជីវិតនិងគ្រួសារតទៅ ។ តែខ្ញុំយល់ឃើញថា ប្រទេសយើងសព្វថ្ងៃ កំពុងតែមានសេចក្ដីចម្រើនជឿនលឿនទៅមុខជាលំដាប់ គួរណាស់តែយើងជាពលរដ្ឋមានចំណេះវិជ្ជាឲ្យខ្ពង់ខ្ពស់ ដើម្បីជួយធ្វើការបម្រើប្រទេសជាតិ ឲ្យរឹតតែមានវឌ្ឍនភាពខ្ពស់ឡើងទៀត ។ ជាពិសេស, ចំណេះវិជ្ជានេះឯងដែលជួយបន្ដៃឲ្យភ្នែកយើង ឲ្យមើលឃើញទៅឆ្ងាយបានគ្រប់ភូមិភាគសាកល-លោក ហើយនឹងជាគ្រឿងពង្រីកសតិបញ្ញាស្មារតីឲ្យបានធំទូលំទូលាយ អាចគិតនឹងធ្វើបានសព្វទាំងបញ្ហាឬកិច្ចការធំៗ ទោះបីពិបាកដូចម្ដេចក៏ដោយ ។

អាស្រ័យគោលបំណងដ៏ប្រសើរដូចពោលមកខាងលើនេះហើយ បានជាក្មួយខំប្រឹងអត់ធ្មត់តស៊ូ ស្វែងរកវិជ្ជាឲ្យបានជ្រៅជ្រះបន្ដិចតទៅទៀត ដើម្បីជាសេចក្ដីថ្លៃថ្នូរដល់ជីវភាពខ្ញុំនិងគ្រួ-សារទៅថ្ងៃមុខ ព្រោះថាបើយើងមានជំរេះវិជ្ជាខ្ពង់ខ្ពស់ហើយ

ដំណែងយសស័ក្ដិរបស់យើងក៏បានខ្ពង់ខ្ពស់តាមដែរ ឯមាសប្រាក់ និងធនធាននានាក៏កើតមានឡើងតាមនោះ ។

ជាអវសាន, ខ្ញុំសូមបួងសួងដល់គុណព្រះរតនត្រ័យនិងវត្ថុស័ក្ដិសិទ្ធិទាំងឡាយក្នុងត្រៃភព សូមឲ្យជួយបីបមថ្នមរក្សាលោកពូព្រមទាំងគ្រួសារ ឲ្យបានប្រកបតែនឹងសេចក្ដីសុខសម្រាន្តកុំបីឃ្លៀងឃ្លាតឡើយ ។

ដោយសេចក្ដីគោរព

ក្មួយរបស់លោកពូ

## កំរងតែងទី១៥

ប្រធាន.– ពេលមួយអ្នកដឹងដំណឹងថា មិត្តអ្នកម្នាក់កំពុងប្រព្រឹត្តអំពើល្បែងពាលា ចូរអ្នកសរសេរសំបុត្រមួយទៅដាស់តឿនសម្លាញ់នោះ ។

(វិញ្ញាបនប័ត្រ ឆ្នាំ ១៩៥៤)

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម :

- ទីលំនៅ ,
- កាលបរិច្ឆេទ ;

២) តួសំបុត្រ :

- សេចក្ដីនឹករលឹកខ្លះ ,
- ពាក្យលួងលោមពន្យល់ ,
- ប្រាប់កំហុសនៃល្បែង ,

៣) សេចក្ដីបញ្ចប់ :

- ពរស័ព្ទសាធុការ ,
- ហត្ថលេខា ។

## ខ. សេចក្ដីអធិប្បាយ

ភ្នំពេញ, ថ្ងៃទី ៨ មិថុនា ១៩៥៨

ប្រិយមិត្តជាទីរលឹក

អស់កាលជាយូរខែមកហើយ យើងមិនដែលបានជួបគ្នាសោះ ព្រោះរវល់ប្រកបកិច្ចធុរៈផ្ទាល់រៀងខ្លួន ៗ ថ្ងៃនេះជាក័ព្វល្អណាស់ ដោយខ្ញុំបានទទួលដំណឹងអំពីសម្លាញ់ ហើយខ្ញុំរីករាយជាក្រៃលែងដោយដឹងថាសព្វថ្ងៃ មហាមិត្ត បានប្រកបដោយសេចក្ដីសុខដូចសព្វមួយផង តែបែរជារន្ធត់ចិត្តយ៉ាងញាប់ញ័រ ព្រោះឮថា សម្លាញ់កំពុងភ្លេចខ្លួនបោះបង់ការសិក្សាងាកទៅចូលចិត្តប្រព្រឹត្តល្បែងស៊ីសងគ្រប់ជំពូកទៅវិញ ។

មិត្ត! ទុកជាយើងពីរនាក់នៅឆ្ងាយពីគ្នាក៏ដោយ តែថ្ងៃនេះយើងហាក់ដូចជាបានដៃគ្នា នៅជិតគ្នា ដូចកាលដែលយើងធ្លាប់បាននៅរួមគ្នានោះ ។ មហាមិត្ត, ថ្ងៃនេះខ្ញុំសូមអង្វរចិត្តមិត្តសុំមិត្តកុំប្រកាន់ខឹងនឹងខ្ញុំណា៎ះមិត្តណា៎ ព្រោះខ្ញុំនិយាយតទៅនេះហាក់ដូចជាហ៊ានតាំងខ្លួនធ្វើជាគ្រូទូន្មានសម្លាញ់ ។ ប៉ុន្តែមិនមែនទេ គឺខ្ញុំនិយាយក្នុងឋានៈជាប្រិយមិត្តរបស់ឯង ដ៏ប្រកបទៅដោយសុទ្ធចិត្តពិតៗទៀតផង ។ អើ! បើទុកជាមិត្តខឹង ក៏ខ្ញុំនៅតែប្រកាន់ថា មិត្តនឹងខ្ញុំប្រាកដជាសម្លាញ់ស្រឡាញ់គ្នាហាក់

ដូចជាមានជីវិតរួមគ្នាតែមួយ ប្លែកតែត្រង់មានរាងកាយជាពីរ
ប៉ុណ្ណោះ ។

សំឡាញ់! បើតាមខ្ញុំសង្កេតមក ធម្មតាល្បែងពាលាទាំង
នោះ មិនដែលទាញមនុស្សអ្នកប្រព្រឹត្តឲ្យបានថ្លៃថ្នូរឡើយ
ឃើញតែទាញឲ្យខូចកេរ្តិ៍ឈ្មោះ ឲ្យអាប់ឱនកិត្តិយស នឹងឲ្យ
ទៅជាជនថោកទាបតែប៉ុណ្ណោះ ។ មួយវិញទៀត វារុញច្រាន
អ្នកប្រព្រឹត្តឲ្យធ្លាក់ចុះក្នុងរណ្ដៅទុក្ខវេទនា រហេមរហាម ទឹកភ្នែក
ព្រឹកល្ងាចក៏មាន ។ ជួនកាល អំពើអកុសលនេះ វាធ្វើឲ្យ
យើងមានរោគាពាធថែមទៀតផង ព្រោះថាដល់យើងដក់លេង
មនទែនទៅ វាធ្វើឲ្យក្រូបបាយ ក្រូបទឹក ក្រូបទាំងដំណេកខុស
ប្រក្រតី ។ មហាមិត្ត! ដល់ទីបំផុតទៅ វានឹងធ្វើឲ្យអ្នកប្រព្រឹត្ត
កាយខ្លួនទៅជាមនុស្សអនាថាគ្មានគេរាប់រក ជួបតែនឹងសេចក្ដី
ទុក្ខសោករហូតដល់ផុតជីវិត ។ ម្យ៉ាងទៀត វាមិនគ្រាន់តែធ្វើ
ឲ្យទៅជាមនុស្សអនាថាទេសំឡាញ់ មនុស្សអកុសលរបៀបនេះ
នឹងក្លាយទៅជាដំបៅអសោចិមួយយ៉ាងធំរបស់សង្គមជាតិ ព្រោះ

វាជាអំពើផ្ដួយនឹងច្បាប់សម្រាប់រដ្ឋ ។

ហេតុនេះ ខ្ញុំសូមអង្វរចិត្តសម្លាញ់ សុំឲ្យសម្លាញ់លះបង់ អំពើលាមកនេះចោលទៅ ដើម្បីកុំឲ្យលោកអ្នកមានគុណ ព្រួយចិត្តដោយសារយើង ព្រោះលោកបានខំចិញ្ចឹមបីបាច់ថែរក្សាយើង តាំងពីតូចមក គ្មានដែលធ្វើឲ្យឈឺសចិត្តអ្វីឡើយ ដោយលោក សង្ឃឹមថានឹងបានជាទីពំនាក់អាស្រ័យរបស់លោកទៅអនាគត ចុះបើយើងនៅតែល្មើសនឹងដំបូន្មានយ៉ាងនេះទៀត តើមិនហា ដូចជាយើងយកភ្នក់ភ្លើង ទៅបង្គីរដុតលើដើមទ្រូង លោកទេ ហើយ ? ម្យ៉ាងទៀត ប្រទេសជាតិកំពុងត្រូវការកំពលរដ្ឋមា ចរិយាល្អ ដើម្បីបំពេញការងារកសាងប្រទេស ឲ្យសមជាប្រទេស ឯករាជ្យ ។ ចុះបើយើងអាល័យតែវល់នឹងល្បែងពាលាដូច្នេះ គ្រឿងករណីយកិច្ចរបស់ពលរដ្ឋសេរីទៅហើយ តើយើងគ្រាន់ ស្អីកងជីវភាពនេះ ?

មុននឹងបញ្ចប់សេចក្ដី ខ្ញុំសូមអង្វរចិត្តមិត្តជាលើកក្រោយ បំផុត សូមឲ្យមិត្តលះបង់គំនិតអាក្រក់នេះចោលអស់ទៅ ហើ

បែរមកស្រាវស្រទេញរៀនសូត្រឲ្យបានម៉ឺនម៉ាត់ឡើងវិញ ដើម្បីសាងអនាគតរបស់យើងឲ្យបានរុងរឿងថ្កុំថ្កើង ប្រកបដោយសុខសម្បូណ៌គ្រប់បែបគ្រប់យ៉ាង ។

ជាអវសាន ខ្ញុំសូមលើកដៃប្រណមបួងសួងដល់វត្ថុស័ក្ដិសិទ្ធិទាំងឡាយក្នុងត្រៃភព សុំឲ្យលោកជួយជម្រះស្មារតីមហាមិត្តរបស់ខ្ញុំ ឲ្យបានល្អប្រសើរដូចដើមឡើងវិញ កុំឲ្យអំពើលាមកចូលមកញាំញីចិត្តរបស់មហាមិត្តខ្ញុំបានទៀតឡើយ ។

# សំបុត្រកិច្ចការឬពាណិជ្ជកម្ម

( Lettres d'affaires ou commerciaux )

## គំរូតែងទី ១៦

ប្រធាន.— ឪពុកអ្នក ទើបតែនឹងបើកហាងលក់គ្រឿងប្រដាប់ទោចក្រយានគ្រប់មុខ ៗ ចូរអ្នកសរសេរសំបុត្រទៅប្រាប់ពួកឈ្មួញនៅខែត្រក្រៅ ឲ្យមកជួយទិញទំនិញទាំងនោះ ៗ

## បរិយាយ

ភ្នំពេញ, ថ្ងៃ ២០ វិច្ឆិកា ១៩៥៧

លោកចាងហ្វាងគ្រឹះស្ថានឧត្តមពាណិជបាត់ដំបង,

ខ្ញុំមានសេចក្ដីរីករាយនឹងជំរាបលោកថា ខ្ញុំទើបតែនឹងបើកហាងថ្មីមួយដាក់ឈ្មោះ " ចក្រពាណិជ" លេខ ៧៥ វិថីព្រះបាទចន្ទរាជា ក្រុងភ្នំពេញ សម្រាប់លក់គ្រឿងប្រដាប់ទោចក្រយានគ្រប់មុខ ៗ

ដូច្នេះ បើលោកត្រូវការទទួលយកទៅលក់រាយតទៅទៀត

នៅខែក្រោយ សូមអញ្ជើញមកផ្ទាល់ឬក៏ផ្ញើសំបុត្របញ្ជាមកខ្ញុំក៏បាន ខ្ញុំនឹងចាត់ចែងផ្ញើទៅជូន ឲ្យបានឆាប់ទាន់ចិត្ត ដោយគិតជូនកម្រៃ ១៥ % លើថ្លៃលក់ទៀតផង ។

សូមលោកទទួលនូវមេត្រីភាពអំពីខ្ញុំ

ហត្ថលេខា

គ. នរេន្ទបុទ្ធិ

គំរូតែងទី ១៧

ប្រធាន.— ឪពុកមាអ្នកទើបនឹងបើកបណ្ណាគារថ្មីមួយ ខ្វះសៀវភៅលក់ជាច្រើន ។ គាត់បានពឹងអ្នកឲ្យសរសេរសំបុត្រមួយ ។ ដូច្នេះចូរអ្នកសរសេរទៅបញ្ជាទិញសៀវភៅតាមបង្គាប់របស់គាត់ ។

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម:

- ទីលំនៅ,

- កាលបរិច្ឆេទ;

២) តួសំបុត្រ:

- សេចក្ដីគួរសម ,

- កាយមុខរបស់ដែលត្រូវទិញ;

៣) សេចក្ដីបញ្ចប់:

- សេចក្ដីនឹករលឹកខ្លះ ,

- ហត្ថលេខា ។

## ១. សេចក្ដីអធិប្បាយ

បាត់ដំបង, ថ្ងៃទី ៧ មីនា ១៩៥៨

ជំរាបមកលោកចាងហ្វាងបណ្ណាគារ សេរីវត្ត

សូមជ្រាប ។

សូមលោកបាត់ការផ្ញើសៀវភៅ ដូចមានកាយឈ្មោះខាង

ក្រោមនេះ៖

៣០ សង្ខេបពង្សាវតារប្រទេសកម្ពុជា ,

២០ អនុពាក្យពិស្ដារ,

២០ រឿងនាងកែវណាម៉ា ខ្សែ១,

២០ " ខ្សែ២,

២០ " ខ្សែ៣,

២០ " ខ្សែ៤,

២០ " ខ្សែ៥

ព្រមទាំងសៀវភៅឯទៀតផងដែលលោកមាន ៗ សៀវភៅទាំងនេះ សូមលោកផ្ញើមកខ្ញុំតាមរថយន្តម៉ុង-ហួត បុះ ដ្បិតធ្លាប់បានដល់ ហើយពួកអ្នករថយន្តធ្លាប់ស្គាល់ខ្ញុំជាយូរមកហើយផង ៗ ជាពិសេស, សូមលោកផ្ញើភ្ជាប់ទាំងវិកយប័ត្រ ដោយរាយតម្លៃសៀវភៅមួយមុខៗ នឹងថ្លៃបូករួមមកផង ដើម្បីខ្ញុំផ្ញើប្រាក់ទៅជូនលោក តាមប្រៃសណីយ៍ នៅវេលាណា ដែលសៀវភៅទាំងនេះមកដល់ហើយ ៗ

បណ្ណាគារប្រទីបខ្មែរ

បាត់ដំបង

# សំបុត្រផ្លូវការនិងសំដែងទឹកចិត្ត

( Lettres officielles & Félicitations )

## គំរូតែងទី១៨

ប្រធាន.— ម្ដាយមីងអ្នកបានមកពឹងអ្នកឲ្យធ្វើពាក្យសុំអនុញ្ញាតលោកចៅសង្កាត់ ដើម្បីសង់រោងធ្វើបុណ្យ ។ ចូរអ្នកសរសេរពាក្យនោះ ។

### ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម :

- ទីលំនៅ ,
- កាលបរិច្ឆេទ ;

២) តួសំបុត្រ :

- សេចក្ដីលំអោន ;
- ឈ្មោះអ្នកសុំ ,
- រៀបរាប់ពីឈ្មោះបុណ្យនោះ ;

៣) សេចក្ដីបញ្ចប់ :

— សំដែងកត្តញ្ញូភាព,

— ហត្ថលេខា ។

## ១. សេចក្ដីអធិប្បាយ

ភ្នំពេញ, ថ្ងៃទី ២៨ មេសា ១៩៥៧

សូមក្រាបប្រណិប័តន៍ចូលមកលោកចៅសង្កាត់លេខ ៦

សូមបានជ្រាប ។

សូមបាននាងខ្ញុំឈ្មោះ សរ - សាយយុត ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ នៅភូមិបឹងកេងកង ក្នុងសង្កាត់លេខ ៦ ក្រុងភ្នំ-ពេញ ។

សូមធ្វើលិខិតនាំចូលមកសុំអនុញ្ញាតពីព្រះគុណម្ចាស់ ដើម្បីសង់ពេងនៅលើចិញ្ចើមថ្នល់មុខផ្ទះនាងខ្ញុំ សម្រាប់រៀបពិធីបុណ្យផ្កា ដែលនាងខ្ញុំព្រមទាំងអ្នកជិតខាងបានរួបរួមកម្លាំងគ្នាកសាងឡើង ទឹងដង្ហែយកទៅវេរប្រគេនព្រះសង្ឃនៅគង់ចាំព្រះវស្សាវត្តលង្កា ក្នុងថ្ងៃសៅរ៍ទី ៣០ មេសា ១៩៥៧ មុខនេះ ដូចមានកម្មវិធីជូនជាប់មកជាមួយនេះស្រាប់ ។

ហេតុនេះសូមព្រះគុណម្ចាស់ មេត្តាអនុញ្ញាតតាមសេចក្ដីសុំ ឲ្យបាននឹងសូមទទួលយកនូវគារវភាពដ៏ខ្ពង់ខ្ពស់របស់នាងខ្ញុំ ។

ហត្ថលេខា

នាងសាយយុត

**កំរូតែងទី ១៩**

ប្រធាន.— បិតាអ្នកប្រាប់ថាសង់តូបមួយលក់សៀវភៅនៅលើខឿនផ្សារ ។ គាត់ប្រើអ្នកឲ្យធ្វើពាក្យសុំ ។ ដូច្នេះចូរអ្នកសរសេរនូវពាក្យនោះ ។

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម:

- ទីលំនៅ ,
- កាលបរិច្ឆេទ ;

២) តួសំបុត្រ :

- សេចក្តីលំឱន ,
- បកតិនាម គោត្តនាម ,
- រៀបរាប់ពីប្រាថ្នារបស់បិតាយើង ;

៣) សេចក្តីបញ្ចប់ :

- អភិវន្ទនកិច្ច ,
- ហត្ថលេខា ។

## ១. សេចក្តីអធិប្បាយ

ភ្នំពេញ, ទី ១៩ ធ្នូ ១៩៥៧

សូមក្រាបប្រណិប័តន៍ ចូលមកលោកអ្នកឧកញ៉ា

សិរីន្ទរបវរសក្តិ ចៅហ្វាយក្រុង ក្រុងភ្នំពេញ

សូមទានជ្រាប ។

សូមទានខ្ញុំបាទឈ្មោះ សុខ-សុវត្ថិ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ នៅផ្ទះលេខ ២៥ វិថីសុធាវង្សក្រុងភ្នំពេញ ។

សូមធ្វើលិខិតមួយច្បាប់នាំចូលមកសុំអនុញ្ញាតពីលោកអ្នកឧកញ៉ាម្ចាស់ ដើម្បីសង់តូបមួយនៅលើខឿនផ្សារចាស់

តីរវិថីឲកញ្ញាផុង សម្រាប់លក់សៀវភៅនិងប្រដាប់ប្រដារៀនសូត្រផ្សេងៗ ។

ដូច្នេះ សូមលោកអ្នកឲកញ្ញាមេត្តាអនុគ្រោះតាមសេចក្ដីនេះឲ្យបាន នឹងសូមទទួលយកនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់របស់ខ្ញុំប្របាទ ។

ហត្ថលេខា

សុទ្ធ - សុវត្ថិ

### គំរូតែងទី២០

ប្រធាន.– នៅឱកាសចូលឆ្នាំថ្មីនេះ ប្រជាជនធ្វើបុណ្យឲ្យបានដោយសេចក្ដីសប្បាយយ៉ាងក្រៃលែង ។ ហេតុនេះបូរអ្នកសរសេរសំបុត្រមួយផ្ញើទៅលោកគ្រូអ្នក ដើម្បីជូនពរដល់គាត់ ។

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម:

- កន្លែង,
- កាលបរិច្ឆេទ;

២) តួសំបុត្រ:

- សេចក្ដីលំនាន,
- សព្វសាធុការពរផ្សេងៗ;

៣) សេចក្ដីបញ្ចប់:

- សំដែងកតញ្ញុតាភាព,
- ហត្ថលេខា ។

## ១. សេចក្ដីអធិប្បាយ

ភ្នំពេញ, ទី១០ មេសា ១៩៥៧

សូមក្រាបប្រណិប័តន៍ចូលមកលោកគ្រូ

សូមទានជ្រាប ។

វេលានេះ ខ្ញុំបាទស្ដាយជាបំផុត ដោយមិនបានមកជូននូវ

ព្វសាធុការពរផ្ទាល់ខ្លួន ចំពោះលោកគ្រូ ។ ខ្ញុំបាទសូមបួង

សួនប្រសិទ្ធីពីចម្ងាយ ក្នុងឱកាសឆ្នាំថ្មីនេះ សូមឲ្យលោកគ្រូមួយ អន្លើដោយគ្រួសារ បានជួបប្រទះតែនឹងជោគជ័យសិរីមង្គលនឹង សេចក្ដីសុខសេចក្ដីចម្រើនជឿនលឿនទៅមុខ គ្រប់ទិនទិវារាត្រីកុំ បីលស់ខានឡើយ ។

ដោយគោរពដ៏ខ្ពង់ខ្ពស់

សិស្សរបស់លោកគ្រូ

សំ-សុមេធ

**គំរូតែងទី២១**

ប្រធាន.– មិត្តអ្នកម្នាក់ទើបបានប្រឡងជាប់មធ្យមសិក្ បត្រថ្មីៗ ។ ចូរអ្នកសរសេរសំបុត្រមួយ ថ្ងៃនសេចក្ដីសាទរបំពេ មិត្តអ្នក ។

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម :

- ទីលំនៅ ,

- កាលបរិច្ឆេទ ;

២) តួសំបុត្រ :

- សេចក្ដីរីកពាយរបស់យើង ;

៣) សេចក្ដីបញ្ចប់ :

- ស័ព្ទសាធុការពរ ;

- ហត្ថលេខា ។

## ១. សេចក្ដីអធិប្បាយ

បាត់ដំបង, ទី ៣ សីហា ១៩៥៧

មកដល់ ហេ ម៉ាលី ប្រិយមិត្ត,

ដោយខ្ញុំបានទទួលដំណឹងពីម្រលមិញថា មិត្តបានប្រឡងជាប់មធ្យមសិក្សាប័ត្រហើយ ។ ខ្ញុំសូមសរសើរដល់ការព្យាយាមក្នុងកិច្ចសិក្សារបស់មិត្ត ដែលខំពុះពារនូវឧបសគ្គគ្រប់យ៉ាង លុះត្រាតែបានសម្រេចដូចបំណងក្នុងវេលានេះ ។ អំពើនេះហើយ

បង្ហាញឲ្យឃើញថា « សេចក្ដីព្យាយាមជាមេសម្រេចផលប្រយោជន៍គ្រប់យ៉ាង » សឹងប្រិយមិត្តបានធ្វើជាគំរូដល់ប្អូនៗជាន់ក្រោយតទៅទៀត ។

ទីបំផុត ខ្ញុំសូមប្រសិទ្ធីពរជូនមិត្តឲ្យបានកប់ប្រសព្វតែនឹងសេចក្ដីចម្រើនជឿនលឿនទៅមុខជាដរាប ។

សម្លាញ់របស់ឯង

សូរ - វង្សឫទ្ធិ

## សុភាសិត

សេចក្ដីណែនាំ ៈ— សុភាសិត គឺជាពាក្យដែលបុរាណាចារ្យបងក្រងទុកមកសម្រាប់ប្រៀនប្រដៅ ធ្វើជាគតិឬចោទជាបញ្ហាទុកឲ្យយើងដោះស្រាយ ។

ការធ្វើអត្ថាធិប្បាយសុភាសិត គឺការវែកញែកពន្យល់សេចក្ដីដែលកប់នៅក្នុងពាក្យសុភាសិត ឬ នៅក្នុងពាក្យទំនឹមទំនៀម ដែលគេបានដាក់ឲ្យយើងធ្វើ ។

ដើម្បីនឹងធ្វើអត្ថាធិប្បាយឲ្យបានច្បាស់លាស់ល្អ ចូរអ្នកប្រកាន់យកតាមគោលការណ៍ដូចតទៅនេះ ៖

១) មុននឹងចាប់សរសេរ ចូរអ្នកពិនិត្យនូវដំណើរនឹងអត្ថន័យរបស់សុភាសិតដែលគេដាក់ឲ្យយើងធ្វើនោះ ហើយអានសាចុះសាឡើងដើម្បីជៀសវាងពីការភ័ន្តច្រឡំ ព្រោះថាបើយើងច្រឡំហើយ មុខជាធ្វើអត្ថាធិប្បាយខុសស្រឡះ ពីន័យដើមរបស់សុភាសិតនោះជាមិនខាន ។

២) ចូរអ្នកពន្យល់ដោយវែកញែកអត្ថន័យ នៃសុភាសិត

នោះជាពីរផ្នែក គឺដំបូងជាអត្ថានុរូប (sens propre) តមកជាអត្ថុបដិរូប (sens figuré) ព្រមទាំងពន្យល់ពាក្យពិបាកទាំងអស់ដែលមាននៅក្នុងសេចក្ដីសុភាសិតនោះ ។

៣) ចូរខំស្រាវជ្រាវរកឧទាហរណ៍យ៉ាងល្អ មកបញ្ជាក់សេចក្ដីលើន័យសុភាសិត ដោយដកស្រង់ពីការងារដែលយើងធ្លាប់ធ្វើ ឬដកស្រង់ពីរឿងដែលយើងបានអានក្នុងសៀវភៅនានា ។

៤) បន្ទាប់មក ចូរអ្នកវិនិច្ឆ័យសេចក្ដីនៃសុភាសិតនោះ ហើយសន្និដ្ឋានសេចក្ដីទុកជាគតិតទៅ ។

**គំរូតែងទី ២២**

ប្រធាន.- ភាសិតមួយពោលថា « ដើមស្អក ឱនដាក់គ្រាប់ » ។ ចូរអ្នកធ្វើអត្ថាធិប្បាយអំពីភាសិតនេះ ។

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម :

- ពាក្យរៀបរាប់យ៉ាងខ្លីដែលមានន័យត្រូវនឹងសុភាសិតនេះ;

២) អង្គសេចក្ដី :

– អត្ថានុរូប , អត្ថបដិរូប ,

– ឧទាហរណ៍បញ្ជាក់ ;

៣) សេចក្ដីបញ្ចប់ :

– យោបល់លើពាក្យសុភាសិតនេះ ។

## ១. សេចក្ដីអធិប្បាយ

ក្នុងលោកសន្និវាសនេះ មនុស្សតែងមានចរិយាប្លែក ៗគ្នា ខ្លះប្រព្រឹត្តសមរម្យតាមគន្លងសីលធម៌ទៅ ខ្លះទៀតប្រព្រឹត្តប្រទ្បីសបើសជាហេតុឱ្យអ្នកផងស្អប់ខ្ពើម ទើបបានបុព្វបុរសរបស់ខ្មែរយើងចងជាពាក្យដំបូន្មានមួយ ដើម្បីទុកទូន្មានដល់កូនចៅជាន់ក្រោយ ថា :

" ដើយស្កក ឱនជាក់គ្រាប់ "

ធម្មតាធញ្ញជាតិទាំងឡាយ មានស្រូវជាដើម កាលដល់រដូវមានផ្លែ គេអាចសង្កេតបានថា ដើមស្រូវណាដែលងើយ ដើមស្រូវនោះមានផ្លែ " ស្កក " គឺជាគ្មានគ្រាប់ គ្មានផល

ប្រយោជន៍អ្វីឡើយ ។

ដើមស្រូវណាដែល "ឱន" ស្រូវនោះប្រាកដជាមានផ្លែ "ដាក់គ្រាប់" ពេញ ពោលគឺមានគ្រាប់នៅក្នុងផ្លែ បានផលយ៉ាងប្រសើរដល់ជនកសិករ ។

នេះជាឧទាហរណ៍ដែលពោលបញ្ជាក់ទៅលើស្រូវ ។ រីមនុស្សយើងវិញ យើងឃើញថា ជនណាដែលវាយឫកលើកកំពស់ អួតក្អេងក្អាង គ្មានចេះគួរសម អាងតែខ្លួនគ្រាន់បើ ជាហេតុឲ្យគេស្អប់ ឲ្យគេជិនណាយ ឬឲ្យគេខ្ពើមរអើមចូលទៅទីប្រជុំណាក៏មិនចុះនឹងគេ ។ សង្គមនាំគ្នាមើលងាយ ជននោះនឹងក្លាយទៅជាមោឃៈឥតមានផលប្រយោជន៍អ្វី ប្រៀបដូចជាស្រូវដែលស្កកយ៉ាងនោះដែរ ។

ផ្ទុយទៅវិញ ជនណាដែលចេះឱនលំទោនមិនធ្វើឫកពាក្រអឺតក្រទមចេះដាក់ខ្លួនប្រាណយ៉ាងសមរម្យ នោះសង្គមនឹងចូលចិត្តរាប់រក ស្រឡាញ់សរសើរ បើជននោះប្រាថ្នាការអ្វីតែងតែបានសម្រេចផលដូចបំណង ប្រៀបដូចជាស្រូវដែលមានផ្លែល្អ អាច

ញុាំងជនអ្នកដាំឲ្យបានផលប្រយោជន៍ប្រសើរយ៉ាងនោះដែរ ។

អាកប្បកិរិយានៃជនទាំងពីរជំពូកនេះ យើងអាចធៀបទៅនឹងបង្កួយក្នុងរឿងធម្មបទក៏បាន ដូចនិទានយ៉ាងសង្ខេបតទៅនេះ

កាលនោះ មានសត្វបង្កួយមួយ អាស្រ័យនៅទីក្លោងទ្វារកំផែងព្រះបរមរាជវាំងនៃស្តេចវិទេហរាស្ត្រ ។ កាលណាព្រះរាជាស្តេចយាងចេញក្តីចូលក្តី បង្កួយតែងគោរពព្រះភូមិន្ទជាដរាប ។ ព្រះនរបតីសព្វព្រះទ័យ ក៏បង្គាប់ឲ្យអាមាត្យធ្វើខ្សែកមាសពាក់ឲ្យបង្កួយជាកិត្តិយស ព្រមទាំងឲ្យនាយពិសេសយកសាច់មកឲ្យបរិភោគជារាល់ថ្ងៃផង ។ ដល់បានគ្រាន់បើបន្តិច បង្កួយឡើងចាង ថ្ងៃក្រោយព្រះរាជាស្តេចយាងមកដល់ក្លោងទ្វារ សត្វកំសត់នេះវាយឫកខេង មិនខ្ចីគោរពព្រះភូមិន្ទដូចពីដើមឡើយ ។ លុះទតឃើញដូច្នេះ ព្រះនរបតីបង្គាប់ឲ្យអាមាត្យយកបង្កួយនោះទៅសម្លាប់ចោលទៅហោង ។

រឿងនេះអាចបញ្ជាក់អត្ថន័យនៃសុភាសិតខាងលើបានយ៉ាងប្រពៃ ហើយយើងអាចច្នៃរកខ្លឹមសាររបស់សុភាសិតនេះឃើញ

ទៀតថា ពាក្យនេះអាចញុំាំងជនទាំងឡាយឲ្យមានឫកពាសុភាព រាបសា ឲ្យចេះទុនលំទោន ប្រើសេចក្ដីគួរសមទៅរកអ្នកផងទាំងពួង ជាហេតុឲ្យអ្នកទាំងនោះរាប់រកហុចផលប្រយោជន៍មកវិញជាមិនខាន ។ ប៉ុន្តែយើងត្រូវចេះទុនលំទោនទៅតាមកាលៈទេសៈ ព្រោះថា មានជនដំពូកខ្លះ កាលបើឃើញយើងទុនហួសពេកទៅ រាមើលងាយរឹតតែនាំគ្នាជាន់ពន្លិចថែមទៅទៀត ។

ដូច្នេះ យើងត្រូវចេះប្រើកិរិយាឲ្យល្មមសមរម្យ ត្រូវទុនក៏ទុន ត្រូវងើបក៏ងើបខ្លះ ដើម្បីជាដំណើរសុខសាន្តសម្រាប់ជីវភាពរស់នៅក្នុងសង្គម ។

## កំរូតែងទី ២៣

ប្រធាន.– បុរាណាចារ្យបានចងបញ្ហាមួយទុកមកថា " គោដំបៅខ្នង ក្អែកហើររំលង រំសាយកន្ទុយ " ។ ចូរអ្នកពន្យល់ ព្រមទាំងទាញយកឧទាហរណ៍មួយមកបញ្ជាក់ន័យរបស់ភាសិតខាងលើនេះ ។

## ក. គោលសេចក្ដី

១) សេចក្ដីផ្ដើម :

- ពាក្យរៀបរាប់យ៉ាងខ្លី ដែលមានន័យត្រូវនឹងសុភាសិតនេះ ;

២) អង្គសេចក្ដី :

- អត្ថានុរូប, អត្ថបដិរូប ,
- ឧទាហរណ៍បញ្ជាក់ ;

៣) សេចក្ដីបញ្ចប់ :

- យោបល់យើងចំពោះបញ្ហានេះ ។

## ខ. សេចក្ដីអធិប្បាយ

ពួកទុជ្ជនតែងប្រើអាកប្បកិរិយាផ្សេងៗ ដើម្បីលាក់កំហុសរបស់ខ្លួន ។ ឃើញជាក់ច្បាស់យ៉ាងនេះ ទើបបានជាបុរាណាចារ្យបង់ជាពាក្យស្លោកមួយបទទុកមកថា ៖

“គោដំបៅខ្នង ក្អែកហើរលេង រំសាយកន្ទុយ”

ធម្មតាសត្វគោ ដែលមានដំបៅខ្នង កាលបើឃើញក្អែក

ហើរលេងពីលើ ទឹកស្រៀវខ្លួន ខ្លាចក្រែងចុះមកទំចឹកបោះដំបៅ កំតាំងលើកកន្ទុយគ្រវីគ្រវាត់ចុះឡើងដើម្បីការពារដំបៅនោះ ។

នេះជាសេចក្ដីត្រង់ តាមន័យរបស់ភាសិត ។ តែងបើយើងវែកញែកតាមន័យប្រៀបវិញ យើងឃើញថា ជនណាដែលបានប្រព្រឹត្តបទអាក្រក់ ឬដែលមានកំហុសអ្វីមួយ តែងខំការពារបិទបាំង ដើម្បីជៀសវាងពីពាក្យនិន្ទា ជៀមជាមរបស់ជនទាំងពួង ។ ប៉ុន្តែបើគាប់ជួនជាមានពាក្យណាមួយដែលនិយាយមករក មានទំនងទាក់ទងនឹងរឿងរ៉ាវសម្ងាត់របស់ខ្លួន ជនទុច្ចរិតនោះឯងរមែងស្រៀវផ្អឹងខ្លួន រអៀសខ្លួនជាដរាប ហើយក៏ខំនិយាយបង្វែរកែសេចក្ដី ដើម្បីកុំឲ្យជាប់ទាក់ទងនឹងសំដីដែលគេបាននិយាយរួចមកហើយនោះ ។ ជួនកាល ធ្វើកាយវិការផ្សេងៗ ដើម្បីបន្ទែបន្ទុំ កុំឲ្យគេសង្ស័យថាខ្លួនជាមនុស្សខូច ។

សេចក្ដីនេះត្រូវនឹងរឿងនិទានមួយ ដូចពណ៌នាតទៅ ៖

មានមន្ត្រីម្នាក់ជាអ្នកស៊ីសំណូក មិនគិតប្រយោជន៍ជាតិឡើយ ។ សម័យនោះ ថ្ងៃមួយមានមិត្តលោកម្នាក់ជាអ្នកគិត

ប្រយោជន៍ជាតិពិតៗ បានទៅលេងផ្ទះលោក និយាយថា "ខ្ញុំឮគេថា មន្ត្រីសព្វថ្ងៃ ច្រើនតែស៊ីសំណូក មិនសូវគិតគូរប្រយោជន៍រាស្ត្រសោះ ឯសារពត៌មានក៏គេចុះពីរឿងនេះញឹកញាប់ដែរ ។

មន្ត្រីម្ចាស់ផ្ទះ រអៀសខ្លួនក៏និយាយថា: "គ្នាក៏ឮអញ្ចឹងដែរ តែបែបដូចជាពេះតែថា-ថាទៅ" ។ រួចលោកបែរមកជានិយាយបន្ទប់ថា: "ម៉េចទៅមិត្ត គិតថាប្រឡងយកបរិញ្ញាបត្រខាងច្បាប់ តើបានប្រុងប្រៀបខ្លះដែរទេ?" ។

រឿងយ៉ាងខ្លីនេះ បញ្ជាក់ថា អ្នកណាមានកំហុសតែងរអៀសខ្លួនជាជរាបរិស័យដូចជាគោដំបៅខ្នង ឃើញក្អែកហើររំលង ខំសាយត្រវីត្រវាត់កន្ទុយយ៉ាងនោះ ។ រីបញ្ហានេះបុរាណបង្ក្រងមក ដើម្បីទុកឲ្យអនុជនជាន់ក្រោយ រៀនសង្កេតរៀនពិនិត្យរកសេចក្ដីពិតលើវាចា និងអាកប្បកិរិយារបស់មនុស្សក្នុងសង្គម ។

បប់

# សិស្សានុសិស្សទាំងឡាយ !

## បេក្ខជនប្រឡងយកវិញ្ញាបនបត្របឋមសិក្សាបំពេញវិជ្ជា

សូមអ្នកកុំភ្លេចឲ្យសោះ នូវក្បួនសៀវភៅសិក្សាដែលគ្មានសៀវភៅណាអាចផ្ទឹមបាន សរសេរដោយអ្នកនិពន្ធល្បីឈ្មោះ ផ្សាយចេញពី

## បណ្ណាគារ សេរីរដ្ឋ

លេខ ៥, វិថីតេជោដំដិន ភ្នំពេញ

សៀវភៅទាំងនោះ ប្រកបដោយរបៀប

ងាយ

ច្បាស់លាស់

ត្រឹមត្រូវ

ទាក់អារម្មណ៍

ល្អវិចិត្រ

គឺ ៖

| | | |
|---|---|---|
| ១ - សង្ខេបពង្សាវតារប្រទេសកម្ពុជា | ២០:០០ | ( រ.គោវិទ ) |
| ២ - អនុពាក្យពិស្តារ | ២៥.០០ | ( " ) |
| ៣ - តែងសេចក្តីខ្មែរ | ២០.០០ | ( " ) |
| ៤ - ប្រែភាសាពន្យល់ | | ( " ) |
| ៥ - ប្រជុំចំណោទ | | ( " ) |
| ៦ - ពាក្យប្រៀបធៀបខ្មែរ - បារាំង ពន្យល់ | | ( " ) |
| ៧ - សម្ពន្ធវេយ្យាករណ៍ថ្នាក់ទី ៤ និងទី៣ ទំនើបជាតិ | ១២:០០ | (គ្រូ.ស៊ិនណារេត) |

រោងពុម្ពអាស៊ីខេមរៈ

២០៛០០